BBI0010

មជ្ឈមណ្ឌលឯកសារកម្ពុជា

# ហួត អេង ហៅ ផាន់ , ភេទប្រុស K00428 (បាត់ខ្លួន)

## គួនាទី អនុបញ្ញាការវរសេនាតូច ៨២

## សម្ភាសន៍ជាមួយ ហួន ឃឹម, អាយុ ៦៣ ឆ្នាំ "ត្រូវជាបងស្រី"

## នៅភូមិកំពង់គល់ថ្មី ឃុំថៃងមានជ័យ ស្រុកបាណន់ ខេត្តបាត់ដំបង ។

## ថ្ងៃទី ៩ កក្កដា ឆ្នាំ២០០៦

## សម្ភាសន៍ដោយៈ រ៉ា ផៃរ៉ាន់

ផៃរ៉ាន់ៈ អ៊ំអត់ទោសអ៊ំ ឈ្មោះអីដែរ?

ឃឹមៈ ឈ្មោះ ហឿន ឃឹម ។

ផៃរ៉ាន់ៈ បាទ! សព្វថ្ងៃអ៊ំអាយុប៉ុន្មានហើយ?

ឃឹមៈ អ៊ំអាយុ ៦៣ ។

ផៃរ៉ាន់ៈ អ៊ំកើតឆ្នាំណាដែរ?

ឃឹមៈ អ៊ំអត់ដឹងកើឆ្នាំអីទេ ៦៣ ហ្នឹង ។

ផៃរ៉ាន់ៈ ឆ្នាំខ្មែរឆ្នាំអីដែរ?

ឃឹមៈ ឆ្នាំខ្មែរឆ្នាំកោ ។

ផៃរ៉ាន់ៈ ឆ្នាំកុរហ្នឹងហ្មែស៎?

ឃឹមៈ ចា៎!

ផៃរ៉ាន់ៈ អ៊ំគ្រួសារឈ្មោះអីដែរអ៊ំ?

ឃឹមៈ ឈ្មោះឡយ ។

ផៃរ៉ាន់ៈ ឈ្មោះអីគេឡយ ។

ឃឹមៈ ហួត ឡយ ។

ផៃរ៉ាន់ៈ ហួត ឡយ..?

ឃឹមៈ ចា៎! ទើបខូចបាន ១ ខែកន្លះ ។

ផៃរ៉ាន់ៈ គាត់ឈឺហ្មែស៎?

ឃឹម៖ គាត់ឈឺស្ទះទឹកម៉ូតម៉ៅពេទ្យអត់ទាន់ ។

ឆៃវ៉ាន់៖ ចុះអ៊ំមានកំណើតកើតជានើឯណាដែរ?

ឃឹម៖ ខ្ញុំនៅកំពង់គល់ចាស់ណឹងដដែល ។

ឆៃវ៉ាន់៖ ភូមិកំពង់គល់?

ឃឹម៖ ចា៎!

ឆៃវ៉ាន់៖ ឃុំអី?

ឃឹម៖ ឃុំកំពង់គល់ណឹងបណ្តោយ ។

ឆៃវ៉ាន់៖ ឃុំកំពង់គល់,ស្រុក?

ឃឹម៖ ស្រុក រតនមណ្ឌលពីដើមម៉ៅណាស៎ ។

ឆៃវ៉ាន់៖ អូ..!ពីដើមម៉ៅស្រុករតនមណ្ឌល...មិនមែនស្រុកបាត់ដំបង់ទេ?

ឃឹម៖ ចា៎!

ឆៃវ៉ាន់៖ ចុះស្រុកបាត់ដំបងណឹងគេហៅ នៅ ពេលណា៎?

ឃឹម៖ គេហៅ នៅ ពេលម៉ៅ ៧៩ ហើយ ។

ឆៃវ៉ាន់៖ គេហៅ ស្រុកបាត់ដំបង?

ឃឹម៖ ស្រុកបាត់ដំបង ។

ឆៃវ៉ាន់៖ មិនមែនសម័យខ្មែរក្រហមគេហៅ ស្រុកបាត់តំបងទេ ។

ឃឹម៖ ចា៎! សម័យប៉ុលពតណឹងស្រុកស្តៅ ។

ឆៃវ៉ាន់៖ រតនមណ្ឌល?

ឃឹម៖ ចា៎!

ឆៃវ៉ាន់៖ ចុះបច្ចុប្បន្នអ៊ំរស់នៅភូមិឃុំអីដែរ?

ឃឹម៖ បច្ចុប្បន្ននេះនៅភូមិឃុំចែងមានជ័យ ភូមិកំពង់គល់ថ្មី ស្រុកបាណន់ ខេត្តបាត់ដំបង ។

ឆៃវ៉ាន់៖ ចុះអ៊ំមានកូនចៅប៉ុន្មាននាក់ដែរ?

ឃឹម៖ អ៊ំមានកូនចៅ ៤ នាក់ ។

ឆៃវ៉ាន់៖ ស្រីប៉ុន្មាន? ប្រុសប៉ុន្មាន?

ឃឹម៖ ស្រី ១ ប្រុស ៣ ។

ឆៃវ៉ាន់៖ សព្វថ្ងៃនៅជុំគ្នាទាំងអស់?

យឹមៈ នៅជុំគ្នាទាំងអស់គេមានប្រពន្ធបែកហើយ សព្វថ្ងៃនៅពីរនាក់កូនលីវមួយស្រី ។

ណែរ៉ាន់ៈ ចុះអ៊ីប្តូរមៅនៅភូមិឃុំនេះតាំងពីឆ្នាំណាមៅ?

យឹមៈ តាំងពី ៧៩ ។

ណែរ៉ាន់ៈ ពេលបែកខ្មែរក្រហមមៅនៅនេះម៉ង?

យឹមៈ គេយករំដោះអ៊ីមៅហ្នឹង ។

ណែរ៉ាន់ៈ ចុះឪពុកម្តាយអ៊ីឈ្មោះអីដែរ?

យឹមៈ ឈ្មោះ ព្រឹល ។

ណែរ៉ាន់ៈ ឪពុកហ្អាស៎?

យឹមៈ ឪពុកឈ្មោះ ហួត ហឿន ។

ណែរ៉ាន់ៈ គាត់សព្វថ្ងៃខូចហើយ ។

យឹមៈ ខូចតាំងពីជំនាន់ណាមៅ?

ណែរ៉ាន់ៈ ខូចតាំងពីជំនាន់ណាខ្ញុំនៅតូចៗ ។

យឹមៈ តាំងជំនាន់ខ្មែរក្រហមទៀត?

ណែរ៉ាន់ៈ តាំងមុនខ្មែរក្រហមទៀត ។

យឹមៈ ចា៎!

ណែរ៉ាន់ៈ គាត់ឈឺហ្អែស៎?

យឹមៈ គាត់ឈឺចាស់ជរាដែរ ។

ណែរ៉ាន់ៈ ចុះម្តាយ?

យឹមៈ ម្តាយក៏ខូចដែរហើយ ឪពុកខ្ញុំខូចតាំងពីជំនាន់សង្គ្រាម ដោយគេសម្លាប់ បើម៉ែខ្ញុំរាប់គាត់ឈឺ ។

ណែរ៉ាន់ៈ បា!ម្តាយស្លាប់ពេលណា?

យឹមៈ ស្លាប់យូរដែរហើយខ្ញុំនៅតូចៗ ។

ណែរ៉ាន់ៈ ស្លាប់ជំនាន់សង្គ្រាមដែរ?

យឹមៈ ក្រោយសង្គ្រាមមៅ ។

ណែរ៉ាន់ៈ ស្លាប់ក្រោយឪពុកទេហ្អែស៎?

យឹមៈ ក្រោយឪពុកទេ ។

ណែរ៉ាន់ៈ ក្រោយយូរដែរហ្អែស៎?

យឹម: ក្រោយយូរដែរ

កាលណឹងខ្ញុំនៅតូចៗនៅឡើយខ្ញុំអត់ដឹងពុតែតាខ្ញុំអ៊ំខ្ញុំគាត់និយាយប្រាប់ថា ម៉ែឯងស្លាប់យូរហើយចៅ ។

នៃរ៉ាន់: បាទ!

យឹម: ណឹងហើយអ៊ំអត់សូវដឹងដែរ ។

នៃរ៉ាន់: បាទ!ចុះឪពុកថាស្លាប់ជំនាន់ឥស្សរៈណឹងពីណាអ្នកសម្លាប់?

យឹម: ពួកខាងស្អីគេអ៊ំអត់សូវដឹងដែរ គេហៅទៅសម្លាប់ជំនាន់ឥស្សរៈណឹងបណ្ដោយ ។

នៃរ៉ាន់: ចុះអ៊ំមានបងប្អូនប៉ុន្មាននាក់?

យឹម: មានបងប្អូនអ៊ី ម្នាក់ឯងគត់ ។

នៃរ៉ាន់: ពីដើមម៉ោហ្អាស់?

យឹម: ពីដើមម៉ោមានបងប្អូនបីនាក់ ។

នៃរ៉ាន់: បីនាក់ណឹងគិតទាំងអ៊ំហ្អែស់?

យឹម: ចាំ!

នៃរ៉ាន់: ស្រីប៉ុន្មាន? ប្រុសប៉ុន្មាន?

យឹម: ស្រី ១ ប្រុស ២ ។

នៃរ៉ាន់: ស្រីតែអ៊ំម្នាក់ទេ?

យឹម: ស្រីតែអ៊ំម្នាក់ទេ...

នៃរ៉ាន់: អ៊ំកូនទីប៉ុន្មាន?

យឹម: កូនទី ១ ។

នៃរ៉ាន់: ចុះកូនទី ២ ឈ្មោះអី?

យឹម: កូនទី ២ ឈ្មោះ ដូ ។

នៃរ៉ាន់: អីដូ?

យឹម: ហឿន ដូ ។

នៃរ៉ាន់: ស្រីឬប្រុស?

យឹម: ប្រុស ។

នៃរ៉ាន់: សព្វថ្ងៃគាត់នៅរស់ឬក៏ស្លាប់?

ឃឹមៈ ស្លាប់អស់ហើយ ។

ឆៃរ៉ាន់ៈ ស្លាប់តាំងជំនាន់ណា?

ឃឹមៈ ស្លាប់ជំនាន់នេះឯង ស្លាប់ឆ្នាំ ២០០០ ប៉ុន្មាន...

ឆៃរ៉ាន់ៈ អូរ!គាត់ឈឺហ្អែស?

ឃឹមៈ ឈឺរោគថ្លើមក្រិន..

ឆៃរ៉ាន់ៈ ចុះទីបីឈ្មោះអី?

ឃឹមៈ ទី ៣ឈ្មោះ ហួត អេង ណឹងឯង ។

ឆៃរ៉ាន់ៈ ហួត អេង ណឹងកាលជំនាន់ខ្មែរក្រហមគាត់ដាក់ឈ្មោះ ដាន់ណឹងហ្អែស៎?

ឃឹមៈ ឈ្មោះ ដាន់...

ឆៃរ៉ាន់ៈ អីចឹងគាត់កូនពៅ គេ.?

ឃឹមៈ កូនពៅ គេ ។

ឆៃរ៉ាន់ៈ អ៊ំដឹងថាគាត់កើតឆ្នាំអីដែរអត់?

ឃឹមៈ អ៊ំអត់ដឹងថាឆ្នាំអីទេ ។

ឆៃរ៉ាន់ៈ ឆ្នាំខ្មែរណឹង...?

ឃឹមៈ ឆ្នាំខ្មែរណឹងអ៊ំអត់ចាំដែរ ។

ឆៃរ៉ាន់ៈ ចុះប្អូនអ៊ំប៉ុន្មានឆ្នាំ?

ឃឹមៈ កូនវាររង្វើលៗដែរណា៎ ធំមួយ មួយទៀត ។

ឆៃរ៉ាន់ៈ បាទ! អត់ចាំថាប្អូនអ៊ំប៉ុន្មានឆ្នាំទេហ្អ៎?

ឃឹមៈ ប្អូនប្រហែល ៤ ឆ្នាំ....?

ឆៃរ៉ាន់ៈ បាទ! អត់អីទេអ៊ំ ...តែដឹងថាប្អូនអ៊ំ ៤,៥ ឆ្នាំដែរហ្អែស៎?

ឃឹមៈ ហ្នឹងហើយ ។

ឆៃរ៉ាន់ៈ អេងណឹងកើតនៅភូមិកំពង់គល់ណឹងដែរ?

ឃឹមៈ ចា៎! កើតនៅភូមិកំពង់គល់ចាស់ណឹងទាំងអស់គ្នាកូន ។

ឆៃរ៉ាន់ៈ ចុះដូចថាកាលពីក្មេងៗគាត់មានបានរៀនអីដែរអត់?

យឹម: រៀនដែរដូចថាមិនបានថ្នាក់ខ្ពស់អីទេកូន អេឯណឹងណា៎ ប៉ុន្តែមនុស្សវាឆ្លាត រៀនអត់បាន ថ្នាក់ខ្ពស់ទេ ម៉ែណឹងមានកូន ៤ ណឹងម្ដាយមីងឪពុកមារណឹងអត់កូន...

នែរ៉ន់: មានកូន ៤ ឬក៏ ៣..?

យឹម: កូន ៣ ណឹងម្ដាយមីងឪពុកមារអត់កូន អត់កូនសុំបងកូន ១ ឲ្យកូនអេឯណឹងទៅ នៅជាមួយបងធ្វើកូនរបស់បង..បងប្រុសហ្អស់..

នែរ៉ន់: បាទ!

យឹម: នៅពេលណឹងកើតខ្មែរក្រហមឡើងគេឲ្យទៅខាងកកោះណឹងហ្អស់...

នែរ៉ន់: កកោះអីណាទៅ?

យឹម: អ៊ឹក៏មិនដែលស្គាល់ដែរ...

នែរ៉ន់: នៅបាត់ដំបងណឹងដែរហ្អែស៎?

យឹម: នៅបាត់ដំបងណឹងដែរហ្អែស៎

នៅកកោះណឹងក៏គេចូលធ្វើការនៅកកោះណឹងទៅ ៗដល់ចូល

ខ្មែរក្រហមណឹងវាបាត់រហូត...បាត់យូរដែរណា៎ ៤,៥ឆ្នាំបានជួបប្អូន ៗ

នែរ៉ន់: បាទ!

យឹម: ៥ ឆ្នាំគេរំដោះណាកូន គេរំដោះពីព្រៃមៅ៉

អ៊ឹមៅ៉នៅនឹងស្រែសព្វថ្ងៃគេហៅកំពង់គល់ចាស់ រួចក៏ដឹងដំណឹងប្អូននៅផ្សារលើ ថា ដាន់ ឃើញហើយនៅផ្សារលើកាន់ខាងកាំភ្លើងធំ ៗ

នែរ៉ន់: អូ..!

យឹម: គេទៅយកខ្ញុំ គេបើកឡានទៅដាក់នៅនឹងរោងចក្រ ខ្ញុំពរកូនពីស្រែមៅ៉ជិះឡានពីរោងចក្រណឹង គេយកទៅហ្អស់ ៗ ណឹងលើកទី ១ មានប្អូនថ្លៃខ្ញុំប្ដីមីប្អូនខ្ញុំណឹងណាស់..ប្អូន ខ្មោចដូណឹង ណា៎ គេធ្វើការនៅបាណន់ គេធ្វើការធំដែរគេទៅយកបង

ទៅគេជូនទៅបងនៅផ្សារ លើណឹងណា៎កន្លែងផ្ទះតុងហាំចាស់ណឹងណា៎ ៗ

ខ្ញុំទៅពីណឹងទៅ គេមិនទាន់រៀបចំកន្លែងអី ប៉ុន្មានទេកូន អោយបងដេកនៅជាមួយខ្ញុំ ៣,៤ យប់ទៅ ..ដែលបងបែកប្អូនយូរហើយ ៗ

អីចឹងដេកក៏ដេកដែរអូន...បងអីណោះក៏អត់ទៀតណា៎វាអតរត់ត្រដេបជ្រាបមៅ៉ទៀតរកអង្ក

រកស្រូវស៊ីគ្មាន អត់បានធ្វើស្រែរលំរត់ឡើងរត់ចុះ ។ ក៏ប្អូនទៅសុំសេដ្ឋកិច្ចឲ្យអង្ករ ១ តៅ ស្ករ ៣,៤គីឡូមៅអោយបង ។

នៃរ៉ាន់: អេងណឹងហ្អែស៎?

ឃីមៈ

អេងណឹងណា៎គេនៅខាងសេដ្ឋកិច្ចនៅលើគេទាំងអស់ត្រីគេដឹកមៅទាំងឡានៗ មៅវាសប្បាយ ស៊ីណាស់កូន...វានៅលើគេទាំងអស់ ។ នីរសាគេ ៨,៥អីចឹងហ្អាស៎ មៅសប្បាយ..ឡានគេ បើកជូនអ៊ំដើរលេងវាបែកចាន...អូយ..ស្រួលបង្ហាញបងអានេះអីចេះៗដែលបងអត់ដែលដឹង ។ ឡើងកប៉ាល់ជិះកប៉ាល់មិនដែលឃើញវាលបែកចានយ៉ាងម៉េទេណា៎ជំនាន់ណឹងនោះ កូន ។

នៃរ៉ាន់: វាលបែកចាននៅអីណាវិញ?

ឃីមៈ វាលបែកចាននៅ បាត់ដំបង កន្លែងកប៉ាល់ហោះចុះណឹងហ្អាស៎ ។

នៃរ៉ាន់: អូ..!

ឃីមៈ

អាកប៉ាល់ខូចត្រង់ណាគេប្រាប់អ៊ំអស់ហើយ..អស់ចិត្តហើយប្អូនអ៊ំរាប់ទៅបិទផ្អែកជិតហើយ បានប្អូននាំបងឃើញអីចឹងណាស៎ ។ បងអ្នកស្រុកស្រែសុខសាទ..ប្អូនអ្នកព្រៃសុខសាទ ។

នៃរ៉ាន់: អ៊ំនិយាយជាមួយគាត់អីចឹងហ្ហែស៎?

ឃីមៈ និយាយអីចឹង ។

នៃរ៉ាន់: បាទ!

ឃីមៈ ហឹគេបើកខោអាវអង្រឹងអីណឹង អ៊ំទៅណឹងត្រូវគេបើកខោអាវអង្រឹងភួយ មុង អីឲ្យកូនទាហានហ្អាស៎ ។

នៃរ៉ាន់: បាទ! អ៊ំសុំសួរបកក្រោយបន្តិចកាលគាត់រៀននៅក្មេងៗអីរៀននៅសាលាណា?

ឃីមៈ សាលាវត្តកំពង់គលំណឹងឯង ។

នៃរ៉ាន់: សាលាវត្តកំពង់គលំណឹង?

យឹមៈ ចាំ! សាលសារៀនគេធ្វើនៅវត្តណឹង ។

ផៃរ៉ាន់ៈ អ៊ំចាំទេគាត់រៀនបានប៉ុន្មានឆ្នាំដែរ?

យឹមៈ បានប្រហែលថ្នាក់ ៤ ដែរ ។

ផៃរ៉ាន់ៈ បួនឆ្នាំដែរហ្អស់?

យឹមៈ ចាំ! យើងថ្នាក់ ៤ កាលណឹងវាគ្រាន់ដែរណាកូន ។

ផៃរ៉ាន់ៈ គាត់ចេះសរសេរអានអីបាន?

យឹមៈ ចេះសរសេរអានគ្រប់សព្វអស់ ។

ផៃរ៉ាន់ៈ គាត់រៀនពូកែដែរ?

យឹមៈ រៀនពូកែដែរវាឆ្លាតដែរណឹង ។

ផៃរ៉ាន់ៈ ម៉េចបានគាត់រៀនបានត្រឹមថ្នាក់ទី ៤ អីចឹង?

យឹមៈ ចុះបើនៅនឹងម្តាយមីង ចុះដែលយើងរត់ទៅវាអត់ទាន់ពេញវ័យល្អទេណាំ

ដូចថាអាយុទើប ១៣,១៤អីចឹងណាកូន ។

ផៃរ៉ាន់ៈ អូ.!គាត់ឈប់រៀនណឹងដោយសាររត់ទៅធ្វើខ្មែរក្រហម ។

យឹមៈ អីចឹងកូនរត់ទៅខ្មែរក្រហម ។

ផៃរ៉ាន់ៈ ឆ្នាំណាគាត់រត់ចូលគាត់រតចូលទៅធ្វើខ្មែរក្រហម?

យឹមៈ យីអ៊ំអត់ចាំឆ្នាំទៀត...មិនដឹងឆ្នាំ ៦០ប៉ុន្មាន ៦៦,៦៧អីណឹង...ឆ្នាំ៦៦ ។

ផៃរ៉ាន់ៈ ៦៦ អីចឹងគាត់រត់ទៅតាំងមុនរដ្ឋប្រហារទៅទៀត...

យឹមៈ ចាំ! ហ្អីកូនខ្មែរក្រហមគេហែចូលភូមិអ៊ំហ្នឹង..បដិសេធន៍ទម្លាក់មេឃុំចោលទាំងអស់ ។

ផៃរ៉ាន់ៈ អូ!ខ្មែរក្រហមគេចាប់ផ្តើមហែចូមភូមិណឹងពីឆ្នាំណាមៅ?

យឹមៈ ពី ៦៦,៦៧ ។

ផៃរ៉ាន់ៈ ណឹងចាប់ផ្តើមព្ធឈ្មោះខ្មែរក្រហម ។

យឹមៈ ចាប់ផ្តើមមានឈ្មោះខ្មែរក្រហម...អ៊ំអីអត់ដឹងទេភ្ញាក់ខ្លួនដូចទាអីចឹងកូន

ភ្ញាក់មិនដឹងថាខ្មែរក្រ

ហមយ៉ាំងម៉េចៗហ្អស់..គេហែរគ្រាន់តែភ្ញាក់ពីដេកឡើងបដិសេធន៍ៗមៅពីកើតមៅ ៗលើក

រំបិតលីដំបងមៅនៅមុខផ្ទះមេឃុំ ។

ផៃរ៉ាន់ៈ បាទ!

យឹម៖ ឆ្នាំដែលគេរដ្ឋប្រហារណឹងណាកូន ។

ផៃរ៉ាន់៖ ឆ្នាំដែលពួកឈ្មោះខ្មែរក្រហមឆ្នាំដែលសម្តេចរដ្ឋប្រហារណឹងហ្អែស៎?

យឹម៖ ណឹងហ្អើយកូន ។

ផៃរ៉ាន់៖ អីចឹងឆ្នាំ ៧០ ហ្អែស៎?

យឹម៖ អ៊ំអត់ដឹងថារដ្ឋប្រហារឆ្នាំណា ។

ផៃរ៉ាន់៖ អីចឹងឬថាគាត់ចូលខ្មែរក្រហមណឹងឆ្នាំ ៧០ ពេលគេធ្វើរដ្ឋប្រហារណឹងហ្អែស៎?

យឹម៖ ហ្នឹងហ្អើយ ។

ផៃរ៉ាន់៖ ចុះពេលគាត់ឈប់រៀនណឹងឈប់ពេលអាគាត់ចូលណឹងឬក៏ឈប់ពេលរត់?

យឹម៖ ឈប់រត់ចូលណឹងបណ្តោយទៅ ចុះយើងមានសាលាអីណារៀនយើងរត់ទៅចូលព្រៃអស់ហើយណឹង ។

ផៃរ៉ាន់៖ អូ! តាំងឆ្នាំ ៧០ អីណោះ?

យឹម៖ ហ្នឹងហ្អើយ ។

ផៃរ៉ាន់៖ គាត់ចូលពេលពួកថារដ្ឋប្រហារទម្លាក់សម្តេចណឹងហ្អែស៎?

យឹម៖ ណឹងហ្អើយ ។

ផៃរ៉ាន់៖ កាលណឹងគេហៅខ្មែរក្រហមឬ...?

យឹម៖ អត់ទេ...គេហៅខ្មែរក្រហមបណ្តោយ ។

ផៃរ៉ាន់៖ កាលគាត់ទៅណឹងគាត់អាយុប៉ុន្មាន?

យឹម៖ អាយុប្រហែល ១៧,១៨ ។

ផៃរ៉ាន់៖ អូ!ធំដែរហើយ...

យឹម៖ ១៧ចុះ ។

ផៃរ៉ាន់៖ អាយុ ១៧,១៨ ហើយម៉េចទឹមរៀនបាន ៣,៤ថ្នាក់អីចឹង?

យឹម៖ ចុះបើរៀនមិនដិតដល់ រវល់ជួយធ្វើស្រែ រវល់មើលគោ,ក្របី អីចឹងយើងអ្នកស្រែ យើងអ្នកព្រៃមិនបានរៀនដិតដល់ទេ ព្រោះអីវាខ្វះជីវភាពរស់នៅហ្អាស៎កូន ។

ផៃរ៉ាន់៖ អីចឹងនៅនេះពីមុនសុទ្ធតែព្រៃហ្អង?

យឹម៖ សុទ្ធតែព្រៃ ។

ផៃរ៉ាន់៖ ចុះកាលណឹងភូមិកំពង់គល់ចាស់ណឹងមានប្រហែលប៉ុន្មានគ្រួសាររស់នៅភូមិចាស់គេ?

ឃីមៈ ភូមិចាស់គេមៅភូមិមានជាង ១០០ខ្នង ។

ឆែវ៉ាន់ៈ ជាង ១០០ខ្នង..ជាង ១០០គ្រួសារដែរ...

ឃីមៈ ចា៎! វាដូចថាមានភូមិនេះ ១ ភូមិនេះមួយអីចឹងទូទាំងកំពង់គល់ណឹងវា១០០ជាដែរ ។

ឆែវ៉ាន់ៈ អូ! ១០០ ជាខ្នង...

ឃីមៈ ជាង ១០០គ្រួសារដែរ ។

ឆែវ៉ាន់ៈ តែនៅហ្នឹងអ្នកស្រុកគេរកស៊ី...

ឃីមៈ រកស៊ីធ្វើស្រែចំការ ។

ឆែវ៉ាន់ៈ ធ្វើស្រែចំការ...

ឃីមៈ អត់មានរកស៊ីអីទេ..មានតែស្រែចំការ ។

ឆែវ៉ាន់ៈ អត់មានកាប់ខសលក់ទេ?

ឃីមៈ កាប់ព្រៃ..ធ្វើស្រែចំការកាប់ព្រៃគាស់គល់ ភ្ជួរស្រែចំការ ឃ្វាលគោ ឃ្វាលក្របី ។

ឆែវ៉ាន់ៈ ចុះអ៊ំ នៅក្នុងភូមិអ៊ំរស់នៅណឹងមុនរដ្ឋប្រហាមានដែលឮដំណឹងថាមានខ្មែរក្រហម
មានចលនាបះបោរខ្មែរក្រហមមានដែលឮទេអ៊ំ ?

ឃីមៈ មានដែលឮមុនរដ្ឋប្រហាណឹងវាមៅអុកឡុកភូមិខ្ញុំ ។

ឆែវ៉ាន់ៈ មៅដែរ?

ឃីមៈ មៅដែរដូចថាបាញ់មេឃុំងាប់មួយ ។

ឆែវ៉ាន់ៈ អូ!

ឃីមៈ ដូចថាផ្ទះទាមគេលក់អីចឹងណាកូន ឪពុកធំអ៊ំហ្អាស៎ ឈ្មោះគាត់តារ៉ុតៗ ។

ឆែវ៉ាន់ៈ បាទ!

ឃីមៈ គាត់ទៅដឹកដែរនោះដូចថាក្បាលព្រលប់មៅ ៦ អីណឹងកូន ។

ឆែវ៉ាន់ៈ បាទ!

ឃីមៈ វាចូលបាញ់សំរ៉ុកប្រាវក្នុងផ្ទះគេ ដូចថាគេញបន្កប់ក្នុង
ដូចថាអ្នកក្នុងបើកដៃអ្នកក្រៅបាន ហើយណាកូនៗ អីចឹងឯងអត់ដឹងអី
ឯងអីណោះភ្ញាក់ថាអ្នកណាគេបាញ់អី នៅផ្ទះឈ្មោះ តាយុកៗ
គាត់លក់ទាមលក់ស្រាលក់អី ហើយនាំគេលេងដូចថាលេងបៀតិចទួចអីចឹងណា ។
គាត់ពិសាស្រារួចគាត់ឈរមើលគេ ត្រូវដើងប៉ុន ៣ ថ្ងៃគាត់ខូច មើលអត់ជា ។

នៃរ៉ាន់ៈ បាទ!

ឃីមៈ ងាប់ក្នុងផ្ទះទាមណឹងពីរនាក់ របួស ២ នាក់ របួស ២ នាក់ជាអ៊ំខ្ញុំ១ណឹងគេមើលជា គេ
របួសតិច ។

នៃរ៉ាន់ៈ ចុះអេងណឹងគាត់ចូលខ្មែរក្រហមអាយុប្រហែល ១៧,១៨ ណឹង?

ឃីមៈ ហ្នឹងហ្អើយ!

នៃរ៉ាន់ៈ ដូចថាគាត់ស្ម័គ្រចិត្តទៅឬ...?

ឃីមៈ ស្ម័គ្រចិត្តទៅអីគេគៀរកូន..។

នៃរ៉ាន់ៈ គេគៀទៅ ...

ឃីមៈ គេហែរបាតុកម្មម៉ៅថាអ្នកឯងចេញផុតពីភូមិនេះ ២២ ម៉ោង...១៥នាទី ។

នៃរ៉ាន់ៈ អូ..!១៥នាទី...

ឃីមៈ បើអ្នកណាចេញមិនផុត ១៥ នាទីគឺខ្ញុំបាញ់ចោល ។

នៃរ៉ាន់ៈ អូ!

ឃីមៈ សាហាវណាស់កូន ។

នៃរ៉ាន់ៈ ទាំងអស់គ្នាហ្នង?

ឃីមៈ ទាំងអស់គ្នាម៉ាភូមិចេញម៉ោង ៦ យប់ ម៉ោង ៦ ល្ងាចគ្មានឲ្យយកអីទេគូន ។

នៃរ៉ាន់ៈ ចេញឆ្នាំ ៧០ ណឹងហ្អែស៎?

ឃីមៈ ហ្នឹងហ្អើយ! គ្មានឲ្យយកអីទេគេអំពែរទេះសាឡីអីណឹងឲ្យគ្នាទូលមាប្រវ៉ិចៗ
មិនបាច់យកចាន យកឆ្នាំងអីទេ ២២ ម៉ោង ។

នៃរ៉ាន់ៈ ២៤..

ឃីមៈ អីចឹងក៏ចេញទៅ នៅពួន...

នៃរ៉ាន់ៈ កាលដែល អេង ចេញទៅ ធ្វើខ្មែរក្រហមកាលណឹងគេគៀប្រជាជនចេញដែរ?

យឹម: គៀប្រជាជនចេញដែរហើយផុតពីភូមិដែរហើយ ផុតពីភូមិហើយគេថាបើមានកូនប្រុសដូចកូនឯងអីចឹងអីគេឲ្យធ្វើយោធា ។

នែរ៉ាន់: អីចឹងឆ្នាំ ៧០ គេគៀចេញពីកំពង់គល់ណឹងគេឲ្យទៅ នៅឯណា?

យឹម: យកទៅដាក់ព្រៃ ។

នែរ៉ាន់: ព្រៃអីណាទៅ?

យឹម: វាលចាំងវាលអីណា...ម៉ុំរ៉ៃចាបអីណោះ ដាក់ក្នុងព្រៃរកអីបានស៊ីៗទៅ រកមិនបានស៊ីអត់ទៅ ។

នែរ៉ាន់: បាទ!

យឹម: កាលពីមុនរត់ណឹងកូនគេធ្វើអុប្បយ៉ុបក្នុងព្រៃ គេហៅថាជង្រុកស្រូវណាកូន ។

នែរ៉ាន់: បាទ!

យឹម: ធ្វើនាំគ្នាយកស្រូវទៅដាក់នៅជង្រុកអុប្បយ៉ុបណឹងទៅ
មិនដឹងគេឲ្យយកស្រូវទៅដាក់នៅព្រៃ ធ្វើអីអុប្បយ៉ុបអីវាមិនដឹងអុប្បយ៉ុបណឹងផង ។

នែរ៉ាន់: អុប្បយ៉ុបណឹងជង្រុកស្រូវ?

យឹម: ជង្រុកស្រូវ ទៅដាក់ក្នុងព្រៃ ធ្វើឲ្យខ្ពស់បន្តិចទៅកុំឲ្យជ្រូកព្រៃវាចូលស៊ី អ៊ំទៅដាក់និងគេអីចឹងទៅ ។មានឪពុកមារអ៊ំ...យកទៅដាក់ចោលទៅរកបានស៊ីៗទៅរកមិនបានស៊ីទិញគេ ទៅ ទៅទិញស្រូវគេដល់តាឡូហាលទៃ តិល ព្រែកជីកអីនាទៅណា ទិញគេ ១ តៅ ៥០ ។

នែរ៉ាន់: ចុះអ៊ំពេលដែលគេគៀប្រជាជនទៅណឹង អេង ណាងទៅជាមួយអ៊ំដែរហ្អែស៎?

យឹម: ទៅជាមួយដែរ ។

នែរ៉ាន់: នៅធ្វើការជាមួយគ្នាដែរ?

យឹម: ធ្វើការជាមួយគ្នាដែរតែគេរើសធ្វើយោធាមានកូនប្រុស,ប្អូនប្រុសប្តីយើង ។

នែរ៉ាន់: ពេលគេគៀទៅភ្លាមៗណឹងគេចាប់ផ្តើមរើស?

យឹម: គេចាប់ផ្តើបរើសបាន ១ ខែអីណឹង គេចាប់ផ្តើមរើស ។

នែរ៉ាន់: ពីណាអ្នកចាប់ផ្តើមរើស?

យឹម: មិនដឹងដែរឃើញតែកាំភ្លើងម៉ៅប្រផេងប្រផាំង ។

នែរ៉ាន់: អ៊ំអត់ស្គាល់ឈ្មោះគេទេ?

យឺម: អត់ស្គាល់ឈ្មោះគេទេ គេហៅខ្មែរក្រហមៗ ។

នៃរ៉ាន់: គេមៅពីខាងណាដែរ?

យឺម: មៅពីខាងណាខាងណីអត់ដឹង ។

នៃរ៉ាន់: អត់ស្គាល់ឈ្មោះ..?

យឺម: អត់ស្គាល់ឈ្មោះគេអត់ដឹង ទើបតែឃើញដូចកូនឯងហ៊ីអ៊ីអីចឹងអ៊ីម៉េចស្គាល់ ។

នៃរ៉ាន់: ចុះពេលគេយកអេងណឹងទៅ ពេលណឹងក្មេងៗ នៅក្នុងភូមិណឹងទៅ ច្រើនដែរ...?

យឺម: ទៅ ចើនគ្នាដែរ ទៅ ច្រើនគ្នាអស់អីចឹងបានសព្វថ្ងៃអ៊ីអីណឹងគេហៅភូមិស្រី..មេឃុំគេដាក់ផារភូមិស្រី ។

នៃរ៉ាន់: អូ!

យឺម: វាអស់ប្រុសហើយ

ដល់សព្វថ្ងៃនេះគេឈប់ឲ្យហៅភូមិស្រីគេឲ្យហៅកំពង់គល់ថ្មីវិញទៅ ។

នៃរ៉ាន់: អីចឹងកាលគេយកប្រុសៗ ទៅណឹងអ្នកមានគ្រួសារក៏យកទៅដែរ?

យឺម: ចា៎!យកដែរ..ប្ដីអ៊ីក៏យក កូនអ៊ីក៏យក ប្អូនអ៊ីក៏យក ។

នៃរ៉ាន់: អូ! អោយតែស្រុសយកទៅទាំងអស់ ។

យឺម: ស្រីក៏យកដែរ ស្រីឲ្យតែក្មេងៗ ទៅជួយស្ពាយគ្រាប់អី អង្ករអីយកឲ្យវាស៊ីណាស់..កន្លែងវានៅលើភ្នំលើអីណា៎ ជួយឡើងទៅណាកូន ។

នៃរ៉ាន់: ចុះដូចថាចាស់ៗប្រុសៗអាយុ ៥០,៦០ឆ្នាំ ក៏យកដែរ?

យឺម: យក...ត្រូវយកៗ..ឲ្យតែប្រុសណាមានកម្លាំងពលាំងល្អត្រូវយកៗ ។

នៃរ៉ាន់: ពេលដែលគេមៅយកណឹងគេបង្ខំ...

យឺម: គេបង្ខំឲ្យទៅបណ្ដោយ អត់មានចង់ទៅ ទេគេមៅបង្ខំឲ្យទៅបណ្ដោយ ។

នៃរ៉ាន់: យកទៅណាងគេប្រាប់ថាយកទៅឲ្យធ្វើអីនៅអីណា?

យឺម: គេប្រាប់ថាអោយទៅ ធ្វើយោធា វ៉ៃប៉ុណក់ប៉ាំណាំងអីណាណោះ ។

នៃរ៉ាន់: នៅអីណា?

យឺម: ប្អូនខ្ញុំណឹងណាស់ ។

នៃរ៉ាន់: ប្អូនណឹងហ្អែស?

យឹម៖ ចា៎! ប្អូនណឹងវ៉ៃ ប៉ាណក់បែក ២ ដង គេថាបងជាន់ៗ គេថាពូកែណាស់ បានគេបានឡើង ។

នៃរ៉ាន់៖ ចុះពេលយើងទៅដំបូងគេយកទៅដាក់នៅ ប៉ាណក់ណឹង?

យឹម៖ គ្រៀកយើងយោធាទៅដាក់ត្រង់ណឹងឯងដូចចាប់បញ្ចូកអីចឹង ចាប់ទៅស្ពាយកាំភ្លើង បណ្តោយមានទៅ ហាត់លូនអីណាទេ ។ ចាប់ទៅកន្លែងគេឲ្យស្ពាយកាំភ្លើងបណ្តោយ បាញ់គ្នា កូនហ្អើយកប៉ាល់ទម្លាក់ៗ វេទនាណាស់ ។

នៃរ៉ាន់៖ អ៊ំ ពេលដែលគេយកអេងទៅណឹងក្មេងៗ នៅភូមិកំពង់គល់ណឹងគេកៀទៅឬក៏មានភូមិណាផ្សេងទៅជាមួយដែរ?

យឹម៖ មាន..៣,៤,៥

ភូមិទៅដែរ..នៅភូមិនេះម៉ាកន្ទុបទៅភូមិនោះម៉ាកន្ទុបទៅ មានមេភូមិមេខ្ទង់គេទៅកាន់ក្តាប់អីចឹងទៅកូន ។

នៃរ៉ាន់៖ ចុះកាលដែលអេងទៅណឹង អ្នកដែលទៅជាមួយអេងណឹងប្រហែលប៉ុន្មាននាក់?

យឹម៖ ប្រហែល១០,២០នាក់ដែរណឹង ១៧,១៨នាក់ចុះ ។

នៃរ៉ាន់៖ អូ!

យឹម៖ ដូច ថាកាលណឹងគេមិនរកអ្នកចេះអ្នកដឹងអីទេ គេរកតែអ្នកក្លាហានណឹងបណ្តោយ ។

នៃរ៉ាន់៖ បាទ!

យឹម៖ អ្នកល្ងង់ម៉េចក៏គេយកដែរ ។

នៃរ៉ាន់៖ ចុះកាលដែលគេរើសអេងទៅណឹងដូចថាគាត់ចង់ទៅទេ?

យឹម៖ អត់ចង់ទៅ ..គេយកទៅបណ្តោយ ។

នៃរ៉ាន់៖ គាត់ថាអត់ចង់ទៅអីចឹង ។

យឹម៖ ស្រាប់តែម៉ែឪបងប្អូនវាយំ...ថាវាកូនក្មេងទៅកាន់ស្ពាយ

កាំភ្លើងអូសដីណាស់កូនបាញ់ទៅ បាញ់មៅ៉ណាកូន ។ អាយុវាវែងទឹងដោះម្តាយវាថ្ងៃវាមិនមានគ្រោះថ្នាក់អីទេប្អូនខ្ញុំណា ដឹកថាហកដីងដំណឹងនៅផ្សារលើបណ្តោយ ។

នៃរ៉ាន់៖ អីចឹងពេលដែលគាត់ចេញទៅណឹងដឹងថាគាត់អត់ចង់ទៅ សោះម៉ងហ្អែស៎?

យឹម៖ អត់ចង់ទៅសោះ ។

នៃរ៉ាន់៖ គេបង្ខំឲ្យទៅ ។

ឃឹមៈ ចា៎!

នៃរ៉ាន់ៈ ចុះអ៊ឹមានដែលឃើញអ្នកផ្សេងទៀតដូចថាគេបង្ខំឲ្យទៅ ហើយអត់ព្រមទ្លាំងហ្នាស៎?

ឃឹមៈ អត់ព្រមទៅគឺត្រូវតែទៅ...គឺទៅបណ្តោយ

អត់ព្រមក៏ត្រូវតែទៅចុះយើងខ្លាចរដ្ឋអំណាចគេ ណាកូន មិនបានទៅ គេសម្លាប់ ។

នៃរ៉ាន់ៈ អ៊ីចឹងគេធ្លាប់សម្លាប់ដែរ?

ឃឹមៈ ធ្លាប់សម្លាប់ ប្អូនជីដូនមួយខ្ញុំគេដឹកយកទៅសម្លាប់ដេកថ្ងៃអ៊ីចឹង

ភ្ញាក់ពីដេកអ៊ីចឹងហៅចុះដីដឹក យកទៅសម្លាប់ ។

នៃរ៉ាន់ៈ អាឆ្នាំដែលគេរើសយកទៅ ធ្វើទ័ពហ្នឹង?

ឃឹមៈ អារេកាយ មៅ៉ណឹងណា៎ ។

នៃរ៉ាន់ៈ អត់ទេដូចថាអាពេលដែលគេហៅឲ្យទៅ ធ្វើទ័ពហ្នឹង...

ឃឹមៈ កាលហ្នឹងអត់ទាន់មានទេ ដូចថាមានរដ្ឋអំណាចគេមៅ៉គំរាមយើងយើងខ្លាចគេទៅ ។

នៃរ៉ាន់ៈ អូ!

ឃឹមៈ អត់ទាន់មានសម្លាប់ទេកាលហ្នឹងបើក្រោយមៅ៉បាន ១ឆ្នាំ

បើអ្នកណាមិនស្រួលគេសម្លាប់ៗ សម្លាប់មនុស្សស្រស់ៗ ។

នៃរ៉ាន់ៈ អ៊ីចឹងនៅឃុំនេះឆ្នាំ ៧០ អត់មានលន់ណុលចូលទេ មានតែខ្មែរក្រហម ។

ឃឹមៈ ហ្នឹងហ្អើយពួកខ្ញុំហ្នឹងហើយ ពុតែវាចេះពុតែវាចោះ ដូចខ្ញុំអីដូចថាមិនទាន់ចំណាស់ដឹងអី

ប៉ុន្មាននោះកាលហ្នឹងហ្នាស៎ ។ ដូចជាខ្លាចៗជិនាន់លន់ ណុល មិនដឹងថាលន់ ណុលហ្នឹង

វាយ៉ាងម៉េច បះបោរលន់ ណុល គេចាប់សម្លាប់អ៊ីចឹង ចុះយើងនៅ ក្មេងវាអត់សូវដឹង

ហ្នាស៎ ដូចចាស់ៗចំណាស់អ៊ឹអីណាស៎ ។

នៃរ៉ាន់ៈ ចុះអ៊ឹ អេងហ្នឹងកាលដែលគេយកចូលទ័ពហ្នឹងនៅខាងតំបន់ណា វរៈណាដែរអ៊ឹ.?

ឃឹមៈ អត់ដឹង គ្រាន់តែដឹងថាហាកវ៉ៃព្រែកដីក អេង, វ៉ៃបាណក់ អេង ។

នៃរ៉ាន់ៈ អូពុឈ្មោះអ៊ីចឹង...

ឃឹមៈ ពុឈ្មោះអ៊ីចឹង...

នៃរ៉ាន់ៈ កានហ្នឹងគេហៅឈ្មោះ អេង អ៊ីចឹង?

ឃឹមៈ គេហៅ ផាន់...មានដៃគូរវ៉ាឈ្មោះ សំ..ហើសំណឹងងាប់បាត់ហើយ ដឹងថាងាប់នឹងប៉ាណក់ ណឹងឯងមួយរណ្ដៅ ៥ នាក់ កប៉ាល់ទម្លាក់បាញ់គ្នា ។

ឆែវ៉ាន់ៈ កប៉ាល់ហោះទម្លាក់ហ្អែស៎ ។

ឃឹមៈ ណឹងហ្អើយ..ទ្រូតៗ ងាប់ច្រើនណាស់កាលជនាន់ណឹងតែប្អូនខ្ញុំអត់អីទេ ។

ឆែវ៉ាន់ៈ ចុះអេងតាំងពីគាត់ចេញទៅដំបូងណឹង គាត់ដែលបានម៉ោលេងផ្ទះដែរអត់?

ឃឹមៈ អត់ដែលបានម៉ោជួបបងម្ដងក៏អត់ដែរ ។

ឆែវ៉ាន់ៈ ដែលឮដំណឹងពីគេម៉ោដែរទេ?

ឃឹមៈ ដែលឮដំណឹងពីគេម៉ោថា អេងវ៉ើៗ ថាប្អូនទៅមិនរួចការងារធំណាស់ចោលអត់បាន ។

ឆែវ៉ាន់ៈ ចឹងគាត់មានដែលផ្ញើសំបុត្រផ្ញើអីឲ្យម៉ោទេ?

ឃឹមៈ អត់ដែលទេ ។

ឆែវ៉ាន់ៈ ចុះពេលក្រោយប្រហែលប៉ុន្មានឆ្នាំក្រោយម៉ោបានឮដំណឹងថាគាត់...

ឃឹមៈ ប្រហែលចុះយើងរត់ទៅលើកូន...៥ឆ្នាំគេរំដោះម៉ោ..រំដោះ ៧៥ ។

ឆែវ៉ាន់ៈ បាទ!

ឃឹមៈ ៧៥ ដឹងដំណឹងប្អូនបណ្ដោយ ។

ឆែវ៉ាន់ៈ បាទ! ចុះមុន ៧៥ ណឹង?

ឃឹមៈ មុន ៧៥ អត់ដឹងគ្រាន់តែឮដំណឹងថា អូ..សំ, ផាន វ៉ើប៉ាណក់ វ៉ើព្រែកជីកអីចឹងណាស់៎ ។

ឆែវ៉ាន់ៈ បាទ! ពេលដែលគាត់វ៉ើនៅព្រែកជីកអីណឹងដឹងថាគាត់នៅកងអីអត់?

ឃឹមៈ នៅកងកាំភ្លើងធំណឹង ។

ឆែវ៉ាន់ៈ អូ! កងកាំភ្លើងធំលេខប៉ុន្មាន?

ឃឹមៈ លេខប៉ុន្មានអឹំអត់ដឹង ។

ឆែវ៉ាន់ៈ អត់ដឹងទេ! ចុះអឹំឮដំណឹងម៉ោពីណាម៉ោ..?

ឃឹមៈ ឮញាតិមិត្តក្នុងស្រុកណឹងពេលកូនគេម៉ោអីចឹង
ដូចកូនឯងអីចឹងថាអូ..បងសំនៅអីនេះនៅអី នោះកូនគេម៉ោគេថាអីចឹងណាស់៎
ហើចុះម៉េចមិនឲ្យម៉ោលេងផងអញនឹងណាស់ ។ គេថាការ ងារគាត់ច្រើនណាស់ម៉ោមិនរួចទេ
គាត់ម៉ោមិនរួចទេគាត់ចោលអត់បាន អត់មានអ្នកណា មើលការងារជំនួស អត់ទុកចិត្តគេ ។

ផៃវ៉ាន់ៈ អ៊ីចឹងពេលដែលអ៊ំពូថាគាត់វ៉ៃនៅសមរភូមិនេះសមរភូមិនោះ

អាណឹងគាត់នៅកងកាំភ្លើងធំ

ឃឹមៈ ចា៎!

ផៃវ៉ាន់ៈ អត់ដឹងនៅកងវរៈអីទេ?

ឃឹមៈ អត់ទេ ។

ផៃវ៉ាន់ៈ កងកាំភ្លើងធំណឹងដូចថាមេគេឬក៏ម៉េច?

ឃឹមៈ មេគេ ។

ផៃវ៉ាន់ៈ ពូដំណឹងថាអ៊ីចឹង..?

ឃឹមៈ ពូថាអ៊ីចឹង ។

ផៃវ៉ាន់ៈ អ៊ីចឹងក្រោយមៅបានអ៊ំបានជួបគ្នាជាមួយគាត់ ។

ឃឹមៈ ចុង ៧៥ ។

ផៃវ៉ាន់ៈ ចុង ៧៥ ហើយ...

ឃឹមៈ ចុង ៧៥ ហើយជួបប្អូន ។

ផៃវ៉ាន់ៈ បាទ! អ៊ីចឹងនៅនេះខ្មែរក្រហមកាន់តាំង ៧០ , ៧៥ បានគេរំដោះទូទាំងមៅបាត់ដំបងណឹង

ម៉ងហ្ន៎ ។

ឃឹមៈ ទូទាំងបាត់ដំបង ។

ផៃវ៉ាន់ៈ ពេលគេគេរំដោះហើយបានរយៈពេលប៉ុន្មានបានអ៊ំបានទៅលេងប្អូន?

ឃឹមៈ រំដោះហើយ ៣,៤ខែដែរណាបានទៅលេងប្អូន?

ផៃវ៉ាន់ៈ បាទ! ៣,៤ខែ...

ឃឹមៈ អាណឹងនៅក្នុងព្រៃនៅឡើយទេដល់នេះដឹងពីម៉ែហើយ

នឹងវ៉ែតគេនៅរោងចក្រកកពង់គល់ នេះណា៎គេថា បង

បងដាន់ល្មមទៅលេងបងដាន់ហ្អើយខ្ញុំនៅជាមួយបងដាន់ ធ្វើធំដូចគ្នាណា៎

គេមាននាយាយទូរសព្ទទៅ មៅកាលណឹងណាគេមានតែអ្នកធំទេទូរសព្ទណឹងណា ។ អ៊ីចឹងគេ

ទៅយកខ្ញុំដល់ស្រែណឹង ខ្ញុំក៏ជិះឡានមៅដល់មៅនឹងគេរោងចក្រណឹងគេ ។

ផៃវ៉ាន់ៈ រោងចក្រអីគេ?

យឹម: រោងចក្រអំពៅស្កសរណឹងណ៎ាកូន ពីមុនរោងចក្រអំពៅស្កសរ តែសព្វថ្ងៃវារលាយអស់ ហើយ ។

នៃរ៉ាន់: បាទ!

យឹម: គេហៅ រោងចក្រកំពង់គល់ ។

នៃរ៉ាន់: បាទ!

យឹម: អឺចឹងក្រោយមៅអ៊ំ ទៅ លេង ហើយរ៉ែត ណឹងគេគេទៅ ម៉ែត..គេគេទៅ ថាអោយ ផាត ទទួល ។

នៃរ៉ាន់: ហឺរ៉ែត ណឹងពីណាគេ?

យឹម: រ៉ែតណឹងនៅភូមិជិតគ្នាណឹង ។

នៃរ៉ាន់: បាទ!

យឹម: ប៉ុន្តែសព្វថ្ងៃបាត់ខ្លួនដែរទៅមាស្រុកណឹងណា ថាដឹកទាំងឡានណាកូន ។

នៃរ៉ាន់: បាទ!

យឹម: អឺចឹងក្រោយមៅអ៊ំ ទៅ លេងទៅ ទៅ លេងម្តងអឺចឹងទៅ ..ដូចថាវានឹងកូនអ៊ំ អាធំនេះ ដល់វា នឹកក្មួយខ្លាំងពេកវាផ្តាំបងឲ្យទៅ លេង នឹងក្មួយទៅឲ្យដេក ៤,៥យប់ ។

នៃរ៉ាន់: ចុះមុនណឹងគាត់មានដែលផ្ញើសំបុត្រមៅទេ?

យឹម: អត់ទេដូចថាជាខ្មែរយះអឺចឹង ។

នៃរ៉ាន់: ចុះមិញអ៊ំថានៅ ៧៥ ណឹងអ៊ំ នៅកំពង់គល់អឺណោះទេ... ចុះថា ៧០ គេជម្លៀសទៅណា នោះម៉េចក៏ត្រឡប់មៅដល់ណោះដែរ.?

យឹម: ចុះគេជម្លៀសទៅ លើ..ជម្លៀសពីឆ្នាំប៉ុន្មាន...៦០..

នៃរ៉ាន់: ៧០...

យឹម: ណឹងហ្អើយ!ជម្លៀសទៅ បាន ៥ ឆ្នាំ ដល់បាន ៥ឆ្នាំជម្លៀសមៅវិញ ។

នៃរ៉ាន់: អូ!ដល់ពេលបែកបាត់ដំបងបែកភ្នំពេញណឹងជម្លៀសមៅភូមិចាស់យើងវិញ?

យឹម: ណឹងហ្អើយមៅនៅភូមិចាស់យើងវិញបានដឹងដំណឹងប្អូន ។

នៃរ៉ាន់: អូ! កាលណឹងគាត់ផ្ញើសំបុត្រដឹងតាមណា?

យឹម: ផ្ញើសំបុត្រដឹងតាមខ្មែរយះគេត្រង់ណាត្រង់ណីទេ...ម៉ែត ហើយនឹងរ៉ែតណឹងឯង ។

នៃរ៉ាន់: អូ!

យឺម: គេនៅ រោងចក្រណឹងណា៎ គេស្គាល់អ៊ំដែរណា៎ ។

នៃរ៉ាន់: បាទ! រ៉ែតណឹងគេស្គាល់អ៊ីដែរនៅភូមិជិតគ្នាណឹង ។

យឺម: ដូចភូមិអ៊ុំ ហើយ នឹងភូមិដូងអីចឹងណាស់..ស្គាល់អីចឹងគេថាប្អូនអ៊ំឯងនៅផ្សារលើ នៅកង កាំភ្លើងធំណឹងដែរ ។

នៃរ៉ាន់: បាទ!

យឺម: ក៏គេទៅ យកអ៊ំ ។

នៃរ៉ាន់: ចុះអាពេលគេផ្ញើសំបុត្រមៅណឹងគាត់សរសេរដាក់ម៉េចខ្លះតាមអ៊ំចាំ?

យឺម: សរសេរដាក់ថាឲ្យបងនាំក្មួយទៅលេង ប្អូននឹកបងខ្លាំងណាស់..ព្រោះវាបែកគ្នា យូរឆ្នាំហើយ ណាកូន ។

នៃរ៉ាន់: បាទ!

យឺម: ៥,៦ឆ្នាំហើវាល្មមតែនឹងដែរ ។

នៃរ៉ាន់: បាទ!

យឺម: ក្រែងគេបានប្រពន្ធបានអីណាស់ ។

នៃរ៉ាន់: ហឺសំបុត្រដែលគាត់ផ្ញើមៅណឹងដូចថាមានសាញ្ញេ មានវ៉ៃត្រាអីដែរទេ?

យឺម: អត់ទេ...សាញ្ញេវ៉ៃត្រាខ្លួនគេណឹងឯង ។

នៃរ៉ាន់: បាទ!ដាក់ឈ្មោះគាត់ទៅ..សរសេរដៃហ្អែស?

យឺម: សរសេរដៃអង្គុលីដែរណឹង.. ។

នៃរ៉ាន់: អូ!វ៉ៃអង្គុលីលេខដែរណឹង ។

យឺម: ចា៎!វ៉ៃដែរណឹង ។

នៃរ៉ាន់: ដូចថាគាត់មានដាក់គួនាទីកាត់អីដែរអត់ពេលគាត់សរសេរមៅណឹង?

យឺម: អត់..អត់មានដាក់តួនាទីថាធ្វើអីអត់មានដាក់ ប៉ុន្តែអ៊ំទៅណឹងឃើញថាគេមៅរណេបរណប ហៅសុទ្ធតែបង ចាស់ប៉ុនណាក៏បង ។

នៃរ៉ាន់: អូ!អោយតែឃើញគាត់គេហៅបង?

យឺម: គោរពពីចម្ងាយ អាយុ ៥០,៦០ហើយគោរពបងពី ចម្ងាយទៀត ។

ឆែរ៉ាន់: គាត់វ៉ៃពូកែហ្អែស៎?

ឃីម: វ៉ៃពូកែ មិនដែលថាមានគ្រោះថ្នាក់អីទេព្រោះថាវ៉ៃៗមិនដែលមានគ្រោះថ្នាក់អីសោះ ។

ឆែរ៉ាន់: កាលអ៊ំទៅលេងគាត់ហ្នឹងកូនអ៊ំទៅលេង ហើយចុះគ្រួសារអ៊ំមានទៅលេងជាមួយទេ?

ឃីម: ទៅជាមួយទាំងអស់ ។

ឆែរ៉ាន់: ទៅប៉ុន្មាននាក់?

ឃីម: ទៅកូន១ ម៉ែ ១ ឪ ១..៣ នាក់ ។

ឆែរ៉ាន់: កាលហ្នឹងអ៊ំកូនតែ ១ ទេ?

ឃីម: កូនតែ ១ ទេ ។

ឆែរ៉ាន់: បាទ!

ឃីម: កូនមិនដឹង..ផ្សារលើផ្ទះតុងហាំ កន្លែងប៉ុយរ៉ូ.. ។

ឆែរ៉ាន់: កន្លែងតុងហាំនៅជាប់ផ្សារលើហ្នឹងម៉ង?

ឃីម: ជិតផ្សារលើ នៅផ្សារលើហ្នឹងបណ្តោយ ។

ឆែរ៉ាន់: តុងហាំ?

ឃីម: តែឥឡូវមិនដឹងវាបាក់បែកអីម៉េច កាលហ្នឹងគេវ៉ៃបែកបាក់ដែរណាស់ តែផ្ទះនៅល្អៗដែរណា៎អ៊ំទៅណា៎ ហីមានតែទ័ពគេទេនៅហ្នឹងណា៎ ។

ឆែរ៉ាន់: ផ្ទះគាត់នៅឬក៏កន្លែងធ្វើការ?

ឃីម: កន្លែងផ្ទះវានៅ កន្លែងធ្វើការគេផ្សេង កន្លែងផ្ទះគេនៅផ្សេង ។

ឆែរ៉ាន់: បាទ! ពេលហ្នឹងអ៊ំទៅជួបគាត់ហ្នឹង គាត់មានគ្រួសារហើយឬនៅ?

ឃីម: មានគ្រួសារហើយអត់ទាន់មានកូនទេ..អ៊ំទៅទី ១ មិនទាន់មានកូនទេ អ៊ំទៅទី ៣ វាមានកូន ១ ។

ឆែរ៉ាន់: អូ!អីចឹងអ៊ំបានទៅលេង ៣ ដង ។

ឃីម: ចា៎! ៣ ដង ៤ដងអីណោះ ។

ឆែរ៉ាន់: ចឹងអ៊ំទៅលេងលើកទី ១ហ្នឹងដឹងថាគាត់មានគ្រួសារហ្នឹងគាត់ការតាំងពីឆ្នាំណា...?

ឃីម: គាត់ទើបតែការបានមួយឆ្នាំមិនដឹងការពីឆ្នាំណាទេ ។

ឆែរ៉ាន់: ទឹមការបាន ១ ឆ្នាំ ហើយទៅលេងគាត់ចុងឆ្នាំ ៧៥ ...

យឹម៖ ចុង ៧៥...

ផៃវ៉ាន់៖ ចឹងគាត់ការគាំង៧៤ អីមៅ៉...

យឹម៖ ណឹងការបាន ១ឆ្នាំហើយ ។

ផៃវ៉ាន់៖ ប្រពន្ធគាត់ឈ្មោះអី?

យឹម៖ ប្រពន្ធគាត់ឈ្មោះ វ៉ា ។

ផៃវ៉ាន់៖ អីវ៉ា?

យឹម៖ អីវ៉ា..អត់ដឹង ។

ផៃវ៉ាន់៖ ប្រពន្ធគាត់ណឹងអ្នកស្រុកណាដែរអុំ?

យឹម៖ នៅព្រះម្លូ..។

ផៃវ៉ាន់៖ ខេត្តអី?

យឹម៖ អត់ដឹងខេត្តអី អុំមិនបានសួរថាខេត្តស្អី...មិនដឹងខេត្តបាត់ដំបង មិនដឹងខេត្តពោធិសាត់..។

ផៃវ៉ាន់៖ ចុះប្រពន្ធគាត់ណឹងធ្វើការអីដែរ?

យឹម៖ ធ្វើការពេទ្យ ។

ផៃវ៉ាន់៖ ពេទ្យនៅណាទៅ?

យឹម៖ ពេទ្យគាត់ដេរ ពីដើមកាតដេរ ។

ផៃវ៉ាន់៖ មុន ៧៥....?

យឹម៖ មុន៧៥គាត់ដេរ គាត់ដេរហើយចូលពេទ្យ ។

ផៃវ៉ាន់៖ បាទ! ពេទ្យនៅ...

យឹម៖ នៅផ្សារលើណឹងហ្នឹង ។

ផៃវ៉ាន់៖ ពេទ្យធំរាល់ថ្ងៃណឹងហ្អែស៎?

យឹម៖ ហ្នឹងហ្អើយ ។

ផៃវ៉ាន់៖ កាលជំនាន់ខ្មែរក្រហមពេទ្យណឹងគេហៅ ពេទ្យអីដែរទៅ?

យឹម៖ គេហៅ ពេទ្យ ព-២ ។

ផៃវ៉ាន់៖ ពេទ្យ ព-២ ។ ពេទ្យ ព-២ ណឹងគេសំរាប់ធ្វើអី?

យឹម៖ ដឹងគេសំរាប់ធ្វើអីផងអុំអត់សូវដឹងផង បើមិនដែលចូលកន្លែងគេផង ។

ផៃវ៉ាន់៖ ដូចថាពេទ្យណឹងសំរាប់អ្នករបួស...ជម្ងឺទូទៅ...

យឹម៖ ណឹងហ្អើយអ្នករបួស ជំងឺទូទៅធ្ងន់ស្រាលអីទៅបញ្ចូលទៅ ដេកពេទ្យណឹងទៅ វះកាត់ ។

នៃរ៉ាន់៖ ដូចថាគួនាទីគាត់ណឹងខាងអីទៅ ..ពេទ្យដែរតែដូចថាគាត់ខាងអី ..?

យឹម៖ អត់ដឹង ។

នៃរ៉ាន់៖ គ្រាន់ដឹងថាពេទ្យនែស៎?

យឹម៖ ចា៎! បើអ៊ំនៅណឹងរាល់ថ្ងៃរាល់ខែទៅណឹងអ៊ំដឹងថាតួនាទីគេជាស្អី ។

នៃរ៉ាន់៖ ចឹងគ្រាន់តែដឹងថាពេទ្យទេនែស៎?

យឹម៖ គ្រាន់ដឹងថាពេទ្យ ។

នៃរ៉ាន់៖ ដូចថាពេទ្យវះកាត់...ពេទ្យអី..?

យឹម៖ អត់ដឹង...ដឹងថាពេទ្យៗហើយ

ពីដើមមៅ៉វាចូលកន្លែងគាត់ដេរប្តីគេធ្វើការនៅកន្លែងជិតគ្នាណឹង

នៅ ពេទ្យណឹងក៏នៅជិតកន្លែងវានៅដែរ ។

នៃរ៉ាន់៖ បាទ! ចុះពេលអ៊ំទៅលេងគាត់ណឹងពេលណឹងដឹងថាគាត់តួនាទីអីដែរអត់

ពេលទៅលេងអេងណឹងហ្អាស៎?

យឹម៖ តួនាទីអត់ដឹងថាតួនាទីអីផង ឃើញតែមៅ៉កាំភ្លើងតូចធំមៅ៉...មៅ៉អន្ទុយតិ ៣,៤ សរ

សេរអីនេះនោះអីអ៊ំមិនសូវដឹងដែរ មិនដឹងតួនាទីគេស្អីផង ។

នៃរ៉ាន់៖ បាទ! តែឃើញគាត់មាននីរសាមានអីដែរ?

យឹម៖ មាននីរសា ៥,៦ នាក់ ។

នៃរ៉ាន់៖ អូ!

យឹម៖ មាននីរសាតូចធំបើកឡានជូនទៅណេះទៅណោះប្អូនមិនអត់ទេ ។

នៃរ៉ាន់៖ នីរសាគាត់ ៤,៥ នាក់?

យឹម៖ ៤,៥ នាក់ ។

នៃរ៉ាន់៖ អីចឹងមានន័យថាគាត់ធ្វើធំដែរហើយ?

យឹម៖ ណឹងហ្អើយ..! មានអ្នកដាំបាយដាំអីផ្សេង ។

នៃរ៉ាន់៖ កន្លែងធ្វើការគាត់ណឹងនៅកន្លែងណា?

យឹម៖ អត់ដឹងមិនដែលឃើញកន្លែងធ្វើការគេផង ជួនកាលនៅជិតៗផ្សារលើណឹងឯង ។

នៃរ៉ាន់៖ ផ្ទះគាត់នៅតែពីរនាក់ប្តីប្រពន្ធគាត់ណឹងទេ?

ឃឹមៈ នៅតែពីរនាក់ប្តីប្រពន្ធណឹង នីរសា ៤,៥ ណឹងឯង ហើយអ្នកតូចអ្នកធំអីម៉ោដូចថា១ថ្ងៃ ៤,១០,១៥ នាក់អី ៧,៨ នាក់អីម៉ោរាល់ថ្ងៃ មានចង់ដឹងការងារអីចឹងដូចកូនឯងអីចឹង គេម៉ោពិភាក្សាគ្នាអីចឹង ។សួរអីចេះអីចេះអីចោះ..អ៊ំទៅឃើញតែអីចឹងឯង តែអ៊ំអត់ដឹងមុខការគេជាស្អី ។

ឆៃរ៉ាន់ៈ ចុះអ៊ំមានដឹងអ្នកធំជាងគាត់អីអ៊ំមានស្គាល់ទេ?

ឃឹមៈ មានអ្នកធំជាងគាត់មានតាខ្វែង ។

ឆៃរ៉ាន់ៈ ណឹងធំជាងគេ?

ឃឹមៈ ធំជាងគេ ។

ឆៃរ៉ាន់ៈ ធំជាងគេនៅកងកាំភ្លើងធំណឹង?

ឃឹមៈ នៅកងកាំភ្លើងធំនៅអីគេនៅដើង...អ៊ំមិនស្គាល់ដែរ ឈ្មោះគាត់ តាខ្វែង គាត់នៅស្រុកណឹង ដែរតាខ្វែងណឹងមាឌគាត់ធំក្រម៉ាប់ដុសក្បាលពោះ ។

ឆៃរ៉ាន់ៈ ឈ្មោះដើមគាត់ឈ្មោះអី?

ឃឹមៈ ឈ្មោះដើមគាត់ឈ្មោះតា...

ឆៃរ៉ាន់ៈ រាល់ថ្ងៃណឹងគាត់នៅរស់ទេអីចឹង?

ឃឹមៈ អត់ទេដឹកយកទៅម៉ាស្រេកគ្នាណឹងទាំងអស់គ្នាណឹង ។

ឆៃរ៉ាន់ៈ តាខ្វែងណឹងធំជាង....

ឃឹមៈ ធំជាងគេ...

ឆៃរ៉ាន់ៈ ធំជាងគេបង្អោះខាងកាំភ្លើងធំណឹងហ្អែស៎?

ឃឹមៈ មិនដឹងខាងកាំភ្លើងធំខាងអីអត់ដឹង ។

ឆៃរ៉ាន់ៈ បាទ!

ឃឹមៈ កាន់ទូទៅបណ្តោយ..តាខ្វែងណឹងដូចស្តេចបណ្តោយ ។

ឆៃរ៉ាន់ៈ អូ!តាខ្វែងណឹងខាងទ័ពណឹងធំជាងគេ...?

ឃឹមៈ ចា៎! ឈ្មោះគាត់តាអីពីដើម...

ឆៃរ៉ាន់ៈ ចុះប្រពន្ធតាខ្វែងឈ្មោះអីដែរ?

ឃឹមៈ ប្រពន្ធតាខ្វែងឈ្មោះ រឿម ។

ឆៃរ៉ាន់ៈ បាទ! រឿម អ្នកស្រុកណា?

យឹម: អ្នកស្រុកនៅជិតខ្ញុំដែរ...នៅភូមិសង្កែវា ឃុំកំពង់គល់ដូចគ្នា ។

នៃភ៉ន់: បាទ!

យឹម: ដូចថាឃុំនៅភូមិនេះអីចឹងទៅ ភូមិតាហោស្វាយខាងកើតនេះឃុំនៅអីនេះដែរ ដូចយើងភូមិ ឃុំរួមអីចឹងណា៎ ឃុំចែងមានជ័យឃុំរួមអីចឹងណា៎ ។

នៃភ៉ន់: បាទ! តាខ្វែងណឹងក៏នៅក្នុងស្រុកកំពង់គល់ណឹងដែរ?

យឹម: នៅកំពង់គល់ណឹងដែរ អ្នកឃុំកំពង់គល់ ភូមិសង្កែវា ។

នៃភ៉ន់: សង្កែវាហ្អែស៎?

យឹម: ណឹងហ្អើយ ។

នៃភ៉ន់: តាខ្វែងណឹងចូលជិនាន់ជាមួយប្អូនអីំណឹងដែរ?

យឹម: ចូលជាមួយគ្នាណឹងឯង គាត់រៀងចំណាស់ដូចកូនណោះហើយណាស់ពេលយកគាត់ទៅ ។

នៃភ៉ន់: ចុះក្រៅពីតាខ្វែងណឹងមានពីណាគេទៀតទេ?

យឹម: មានពីណាទៀតទេ ។

នៃភ៉ន់: អត់ស្គាល់ទេ...

យឹម: ដូចថាអ្នកធ្វើការវាមិនបានជាប់ដូចប្អូនខ្ញុំណាស់ ច្រើនតែធ្លាក់អស់ ម៉ាស្រែកវាណឹងគេធ្លាក់អស់ងាប់អស់ នៅតែវាណឹងអត់អី ។ ហឺវាធ្វើការចេះតែឡើងក្រោយពេលរំដោះម៉ោណាកូន ។

នៃភ៉ន់: ពេលអ៊ំទៅលេងគាត់ណឹង គាត់នាំទៅលេងទៅអីណានោះ?

យឹម: ទៅលេងកន្លែងវាលបែកចាន...កន្លែងវាលកប៉ាល់ហោះចុះណឹងណាស់ នាំអ៊ំជិះឡានទៅឲ្យនីរសាបើកឡានទៅមើល ផ្លែលមើលផ្សារណឹងណា៎ ។ អោយបងមើលបងអ្នកស្រែចំការអ្នកព្រៃទឹកន្លែងផ្សារ កន្លែងកប៉ាល់ហោះចុះយ៉ាងណាអត់ដឹងអត់ស្គាល់ អីចឹងនាំបងដើរលេង ។

នៃភ៉ន់: ចុះអីចឹងពេលគាត់នាំអ៊ំដើរលេងអីចឹងដូចថានៅផ្សារអីមានគេលក់គេដូរដែរ?

យឹម: អត់មានទេ...កាលណឹងអត់ទាន់មានទេ ។

នៃភ៉ន់: ស្ងាត់ជ្រាបហ្នឹង...

យឹម: បាយរួមបណ្តោយ...

នៃភ៉ន់: អាពេលនៅបាត់ដំបងណឹងបាយរួម?

យឹមៈ

ណឹងហ្អើយបាយរួមបណ្ដោយកាលណឹង..ដូចថាកងកូនឯងមាក្ដុបទៅ ,កងកូននោះមាក្ដុបទៅ ។

នៃភ័ន់ៈ អ៊ំឃើញអីចឹងកាលណឹងហ្អែស៎?

យឹមៈ អ៊ំឃើញអីចឹង..ប្អូនអ៊ំដឹកត្រីមាកន្ទុយឡានមៅចែក ៣ ក្រុម,ដឹកស្ករសរមារទេះមៅចែក ៣ ក្រុម ដឹកស្អីក៏ដោយអំបិលមារទេះមៅចែក ៣ ក្រុម ប្អូនខ្ញុំណឹងចែក ៣ ក្រុម ដូចថាកងអនុសេនាធំបណ្ដោយហ្មាស៎ ។

នៃភ័ន់ៈ គាត់ចែកអោយ..?

យឹមៈ គាត់ចែកឲ្យ ៣ ក្រុមៗ ។

នៃភ័ន់ៈ អីចឹងគាត់អ្នកដឹកខ្លួនឯងឬមានអ្នកដឹកមៅអោយ?

យឹមៈ មានគេដឹកមៅអោយ ។

នៃភ័ន់ៈ គាត់អ្នកមើលការខុសត្រូវ?

យឹមៈ មើលការខុសត្រូវ អត់មានទៅដឹកខ្លួនឯងទេ ស្អីក៏ដោយអត់មានទៅដឹកខ្លួនឯងទេ គេដឹកមៅ ដល់ផ្ទះ ។ បញ្ជាថាចែកប៉ុណ្ណេះក្រុមប៉ុណ្ណោះក្រុមប៉ុនណឹងឯង ។

នៃភ័ន់ៈ អូ! អីចឹងនៅហ្នឹងហូបចុកគ្រាន់បើដែរ ។

យឹមៈ គ្រាន់បើ..បើទៅផ្ទះតាខ្វែនណឹងវិញអ៊ំទៅ គេឲ្យអ៊ំដេកផ្ទះគេ ២ យប់ដេកផ្ទះគេដេកឡាវលើអីណោះណា៎ ។ មានពីរបីជាន់ឡើងលើអីណោះ អញ្ជើញអ៊ំឡើងទៅមានខ្មោចតាអ៊ំនោះមួយ...មានខ្មោចតាបុគ ១ យាយកេត ១ យាយកេតប្រពន្ធឪខ្ញុំណា៎ ។ គាត់ថាបងកុំទៅមីអូនកុំទៅ ..កាលណឹងកូនខ្ញុំទឹមចេះដើរស៊ីអណ្ដើកខ្លាចទាស់ ។ គាត់ថាមីខ្វិនៗកូនបងឡេងនោះ...មីខ្វិនអ៊ើយកាប់មាន់មួយទៅ ស្ងោរត្រឡាចឲ្យមីឃឹមស៊ីវាកូនខ្ចីខ្លាចវាទាស់ ។

នៃភ័ន់ៈ គាត់ហៅទៅលេងហ្អែស៎?

យឹមៈ ហៅទៅលេង..បងប្អូនសាច់ញាតិណាស៎ ។

នៃភ័ន់ៈ អូ..!ត្រូវបងប្អូនសាច់ញាតិដែរ?

យឹមៈ ណឹងហ្អើយជាប់បងប្អូនសាច់ញាតិណាស៎ ហៅទៅលេងឲ្យទៅដេកណឹង ២ យប់អត់ឲ្យមៅ ទេនាំដើរមើល

ដូចថាដើរមើលទេសភាពគេអីចឹងណា...ដែលក្មួយអីណេះមិនដឹងអី..អានេះឈ្មោះអីចេះអានោះឈ្មោះអីចោះ កន្លែងនេះកន្លែងនោះអីចឹងកូន ។

ឆៃវ៉ាន់: ចុះដើរមើលអីចឹងមានឃើញមនុស្សគេធ្វើការទេ?

ឃឹម: ឃើញគេធ្វើអីចឹងតែមិនដឹងគេធ្វើអីខ្លះទេកូន ។

ឆៃវ៉ាន់: ឃើញគេធ្វើអីខ្លះ?

ឃឹម: ឃើញគេធ្វើការងារអីគេកាប់ធ្វើសំណង់អីគេ ។

ឆៃវ៉ាន់: បាទ! ចុះផ្សារ,វត្តអីមានលោកទេ?

ឃឹម: មិនទាន់មានទេកាលណឹង ។

ឆៃវ៉ាន់: លោកអត់មានដែរ..បិទទ្វារអស់ហើយ?

ឃឹម: អត់ទាន់មានទេផ្សារអីក៏អត់ដែរ កាលណឹងអត់ទាន់មានលុយចាយផង ។

ឆៃវ៉ាន់: អត់មានលុយចាយទេ...?

ឃឹម: អត់មានលុយចាយទេ..លុយចាយដល់ ៧៩ អត់លុយចាយទៀតចាយអង្ករ ។

ឆៃវ៉ាន់: បាទ!

ឃឹម: ទៅផ្សាររៀបអង្ករ ។

ឆៃវ៉ាន់: បា! លើកទី ១ អ៊ំទៅលេងគាត់បានប៉ុន្មាន ៥ ថ្ងៃ?

ឃឹម: ៥ ថ្ងៃ..! លើកទី ២ បាន ១អាទិត្យមិនឲ្យមៅទេនៅធ្វើនំបញ្ចុកស៊ីធ្វើបាញ់ឆែវស៊ី ចង់ស៊ីបាញ់ឆែវបងកុំទាន់ទៅខំបណ្តុះសណ្តែកធ្វើបាញ់ឆែវសិន ។

ឆៃវ៉ាន់: ចុះដូចការងារគាត់ណឹងគាត់ធ្វើការងារនៅកែផ្ទះណឹងហ្នឹង?

ឃឹម:

នៅតែផ្ទះណឹង...ជូនដើរទៅបាត់ៗទៅមៅវិញមានអ្នកតូចមានអ្នកធំមៅ. ។ពេលអ៊ំទៅលើកទី ១ណឹងនំបញ្ចុក ២ កញ្ជ្រែ..ធ្វើទៅអញ្ជើញពីណាពីណឹមានតែកាំភ្លើងខ្លីមៅ ។ អាខ្មៅតាងិលអី ណាក៏ឃើញដែរ ២,៣ គុ អាគុមូលអីចឹងណា ហើយនំបញ្ចុក ២ កញ្ជ្រែអីចឹង ។ ម្ចាស់ខ្ញុំ
ទៅដែរម្ចាស់វ៉ាតខ្ញុំណាស់គាដឹកត្រីមាំកន្ទុយឡានមៅណាស់..ស្ងោរទឹកនំបញ្ចុកបងៗ ។ នំបញ្ចុក ២ កញ្ជ្រែមិនដឹងថាមនុស្សមៅពីណាទេ អានោះមៅបង អានោះមៅបង ។ មៅលេងមៅធ្វើ ការគេហៅមៅស៊ីនំបញ្ចុកណឹងណាស់ ។ ដល់ពេលទី ២

អ៊ំ ទៅ ធ្វើបាញ់ផ្នែវអាណឹងទៅ បាន

១ អាទិត្យបណ្ដុះសណ្ដែក..ព្រោះចង់ស៊ីបាញ់ផ្នែវមិនដឹងបានអីធ្វើខ្ញុំនោះខ្ញុំក៏បាប់អូនហ្អើយ ទៅ រកខ្វាញ់រកដូងមៅ...អីចឹងបងធ្វើអោយស៊ីមាន់ ៣ ដូង ៣ បាញ់ផ្នែវ ១៥ កំប៉ុង ។

ផៃរ៉ាន់៖ លើកទី

២ ពេលអ៊ំ ទៅ លេងគាត់ណឹងប្រហែលប៉ុន្មានឆ្នាំក្រោយមៅបានទៅ លេងគាត់ទៀត?

ឃីម៖ មិនប៉ុន្មានឆ្នាំទេកូនហ្អើយតែ១ខែអីកន្លះខែអីណឹងទៅ លេងទៀតហ្អើយ ។

ផៃរ៉ាន់៖ គាត់សរសេរសំបុត្រមៅហ្អែស៎?

ឃីម៖ សរសេរសំបុត្រមៅផ្ញើតាមម៉ែរ៉េត...ហើយម៉ែរ៉េតទៅ ហៅញាតិគេចេញចូលជិត ។

ផៃរ៉ាន់៖ ចុះអ៊ំ ពេលគាត់ផ្ញើសំបុត្រមៅអីចឹងយើងយកសំបុត្រណឹងទៅ បញ្ហាញមេឃុំមេដែរអត់ ពេលយើទៅ លេង?

ឃីម៖ មេឃុំចង់បង្ហាញក៏បានអត់ក៏បានព្រោះអីមានសាច់ញាតិឯងច្រើនហើយ ដឹងដំណឹងនោះ អរ ។

ផៃរ៉ាន់៖ ឃុំណឹង..?

ឃីម៖ ចា៎! ឃុំណឹងត្រូវជាជីដូនមួយទៀត ។

ផៃរ៉ាន់៖ អូ!

ឃីម៖ មេឃុំណឹងណាស៎ត្រូវជាជីដូនមួយខ្ញុំណឹង ។

ផៃរ៉ាន់៖ អីចរឹងទៅ លេងលើកទី ២ ចុង ៧៥ ដដែលហ្ន៎?

ឃីម៖ ណឹងចុង ៧៥ ហើយ ចូលជិតដាច់ហើយណា៎ ។

ផៃរ៉ាន់៖ ពេលណឹងគាត់មានកូនហើយនៅ?

ឃីម៖ នៅ ។

ផៃរ៉ាន់៖ អាលើកទី ២ ហ្អាស៎ ។

ឃីម៖ អាលើកទី ២ ណឹងមានហើយតែវាអត់ទាន់កើត ។

ផៃរ៉ាន់៖ នៅក្នុងពោះនៅឡើយ?

ឃីម៖ នៅក្នុងពោះនៅឡើយ ។

ផៃរ៉ាន់៖ ចុះលើកទី ១ ពូថាទម្ងន់ដែរ?

យឹម៖ លើកទី ១ ពុថាទម្ងន់ៗដឹងមែនឬក៏កុហក ។

នៃរ៉ាន់៖ បាទ!

យឹម៖ ដល់លើកទី ២ ខ្ញុំឃើញមានផ្ទៃពោះធំ ។

នៃរ៉ាន់៖ លើកទី ២ទៅ លេងបានប៉ុន្មានថ្ងៃ?

យឹម៖ លើទី ២ បានអាទិត្យ ។

នៃរ៉ាន់៖ មាំអាទិត្យគត់ នាំដើរលេងទៀត?

យឹម៖ នាំដើរលេងទៀត ទៅបឹងឯនាំដើរលេងទាំង ៣ ដងឡានជូន ឡានជូនឆ្លងស្ពានថ្មណឹងណា

កូន ។

នៃរ៉ាន់៖ បាទ! ស្ពានថ្មចាស់ណឹងហ្អែស៎?

យឹម៖ ស្ពានថ្មចាស់ណឹង ឆ្លងទៅត្រើយកើតទៅ ប្រពន្ធវ៉ាកាលណឹងនៅត្រើយខាងកើត អ៊ើយ..

ដូង ម្លូ ស្វា បេះមៅផ្ញើបងប្អូនអីណោះណាស៎ ។

នៃរ៉ាន់៖ ចុះជូនទៅ លេងអីចឹងឃើញអ្នកស្រុកគេធ្វើការតាមស្រែទេ?

យឹម៖ ឃើញធ្វើ ឃើញអីដែរ.. ។

នៃរ៉ាន់៖ ឃើញច្រើនទេ?

យឹម៖ ច្រើនដែរ ។

នៃរ៉ាន់៖ ឃើញច្រើនណឹងដូចថា ការរស់នៅគាត់ល់ណឹងម៉េដែរ...គាត់ស្គម ។

យឹម៖ អត់ស្គមអត់ធាត់ធម្មតា មនុស្សណឹងអត់សូវលំបាកចិត្តទេ ។

នៃរ៉ាន់៖ អត់ទេឃើញអ្នកធ្វើស្រែតាម...

យឹម៖ អូ...ស្គមៗគ្នាកាលណឹងខ្វះខាតដែរណា៎ ។

នៃរ៉ាន់៖ ចុះអឹ បានឃើញគេធ្វើដែរកាលណឹង?

យឹម៖ ឃើញគេធ្វើដូចថាស្ទូងស្រូវ កាប់កាស់អី..កាលណឹងមានគោមាអីណាប្រើកូន..កាប់ចប

កាប់អឹ អីណាកូន

កាប់ចបកាប់អីចឹងអ្នកណាគេមានគោប្រើមានទៅ អ្នកណាអត់កាប់ចបកាប់ទៅ

ទ្រួសការបិតក្រដុំកទៅ ។

នៃរ៉ាន់៖ ចុះពេលទៅ លេងគាត់ណឹងអឹដឹងថាកន្លែងគាត់នៅតំបន់អីដែរទេ?

ឃឹមៈ អត់ដឹងទេ ។

ផៃរ៉ាន់ៈ ភូមិភាគអី?

ឃឹមៈ ឮថាភូមិភាគៗមិនដឹងថាភូមិភាគអី ។

ផៃរ៉ាន់ៈ ភូមិផាគពាយ័ព្យ?

ឃឹមៈ អត់ដឹងទេ ។

ផៃរ៉ាន់ៈ អត់ដឹងទេ?

ឃឹមៈ ចា៎!

ផៃរ៉ាន់ៈ ទៅលេងបានម៉ោអាទិត្យដែរ? ហីនីរសាគាត់នាំដើរ...

ឃឹមៈ នាំដើរទាំងអស់គ្នា ទាំងប្ដីទាំងប្រពន្ធនីរសាបើកឡានទៅ ។

ផៃរ៉ាន់ៈ ចុះប្អូនអ៊ំមួយទៀតនោះគាត់អត់ហៅទៅទេ?

ឃឹមៈ ហៅទៅ ...តែគេមានប្ដីទៅជាមួយគេ ២ ដង..មួងលើកក្រោយអត់បានទៅទេ ។

ផៃរ៉ាន់ៈ អីចឹងមានបងប្អូនប៉ុន្មាននាក់?

ឃឹមៈ មានបីនាក់ប្អូនស្រី ១ ប្អូនប្រុស ១ ។

ផៃរ៉ាន់ៈ អូ..!បងប្អូន ៣ នាក់ស្រី ២ ប្រុស ១ ។

ឃឹមៈ អីចឹងលើកទី ២ ទៅលេងគាត់បាន ១ អាទិត្យគាត់នាំដើរលេងទៀត ។

ផៃរ៉ាន់ៈ អ៊ំក្រៅពីតាខ្វែងណឹងអ៊ំអត់មានស្គល់ពីណាទៀតទេ?

ឃឹមៈ អត់មានទេកូន ។

ផៃរ៉ាន់ៈ ចុះពេលអ៊ំត្រឡប់មោ៉វិញអីចឹងនីរសាគេជូនមោ៉ដល់ផ្ទះហ្អែស៎?

ឃឹមៈ គេជូនប្អូនជូនឡានដល់រោងចក្រ នីរសាមោ៉ជិះឡានមោ៉ដល់រោងចក្រទាំងអស់ទាំងប្ដីទាំងប្រពន្ធទាំងនីរសា ។

ផៃរ៉ាន់ៈ ជូនមោ៉ដល់ណឹងទៅ.?

ឃឹមៈ ជូនមោ៉ដល់ណឹងទៅ ខ្ញុំដើរទៅឡានទៅវាមិនដល់ ។

ផៃរ៉ាន់ៈ ចុះលើកទី ១ ក៏ជូនមោ៉ដែរ?

ឃឹមៈ ជូនដែរ..លើកទី ២ ក៏ជូនដែរ.. លើកទី ៣ ប្អូនថ្លៃប្ដីមីប្អូនខ្ញុំ ។

ផៃរ៉ាន់ៈ ប្អូនថ្លៃគេជូនទៅ?

ឃីម៖ ប្អូនថ្ងៃគេជូនទៅ គេធ្វើការធំដែរ ។

នៃភ័ន់៖ ធ្វើការខាងអីគេ?

ឃីម៖ ដឹងខាងអីទេ..។

នៃភ័ន់៖ ធ្វើការជាមួយអេងណឹងដែរ?

ឃីម៖ ទេគេធ្វើផ្សេង ។

នៃភ័ន់៖ ហីស្គាល់ដែរ?

ឃីម៖ ស្គាល់ ។

នៃភ័ន់៖ អាណឹងគេជូនទៅ ?

ឃីម៖ ជូនទៅ ។

នៃភ័ន់៖ ពេលគាត់ហៅម្តងៗដល់តែសរសេរសំបុត្រមៅបានអីបានទៅហ្អែស?

ឃីម៖ ចា៎! សរសេរសឹបុត្រ បើថាស្គាល់ជិតស្និទ្ធអីផ្ដាំមៅ..។

នៃភ័ន់៖ ចុះលើកទី៣ប្រហែលរយៈពេលប៉ុន្មានបានអីបានទៅលេង?

ឃីម៖ ប្រហែលជាមួយខែអី ។

នៃភ័ន់៖ អីចឹងគ្រាន់តែចន្លោះប្រហែលមយយខែៗទេទៅលេង?

ឃីម៖ ចា៎!

នៃភ័ន់៖ ហីលើកទី ៣ កាលទៅលេងណឹងគាត់មានកូននៅ ?

ឃីម៖ មានហើយ..កើតហើយកូនស្រី កើតបានប្រហែលមាអាទិត្យអីអឹ ទៅ ។

នៃភ័ន់៖ អូ!គាត់ឲ្យទៅជួយមើលកូន...

ឃីម៖ ចា៎!ជួយមើល...

នៃភ័ន់៖ អីចឹងចូល ៧៦ ហើយពេលដែលគាត់មានកូនណឹងហ្អែស?

ឃីម៖ ចា៎!

នៃភ័ន់៖ កូនស្រីគាត់ឈ្មោះអីទៅ ?

ឃីម៖ មិនដឹងថាដាក់ឈ្មោះអី...ទើបតែកើតបានមួយអាទិត្យ ។

នៃភ័ន់៖ កូនស្រីគាត់កើតបានមួយអាទិត្យហ្អែស ។

ឃីម៖ កើតនៅពេទ្យក៏កើតនៅផ្ទះ?

នៃភ័ន់៖ ទេនៅផ្ទះឡើយ...

យឺម៖ ដឹងចេញពីពេទ្យហើយក៏មិនដឹង...

នៃរ៉ាន់៖ បា! ពេលលើកទី ៣អ៊ំទៅ លេងណឹងបានប៉ុន្មានថ្ងៃ?

យឺម៖ លេងទី ៣ណឹង ២,៣ ថ្ងៃណឹងមកវិញណឹង ។

នៃរ៉ាន់៖ ម៉េចបានឆាប់មកម៉េស៎?

យឺម៖ ឆាប់មកពោះវារវល់ការងារដកស្ទូង ។

នៃរ៉ាន់៖ អត់អាចនៅ បានយូរទេ?

យឺម៖ មិនអាចនៅ បានយូរទេ...បងនៅមិនបានយូរទេរវល់ដកស្ទូង ។

នៃរ៉ាន់៖ ចុះកាលលើកទី ២ ម៉េចនៅ បានយូរម៉េស៎?

យឺម៖ លើកទី ២វាអត់រវល់ អត់រវល់ហើយប្អូននឹងខ្ញុំងប្អូនឃាត់ឲ្យនៅ ដេកលេងនៅ ដេកលេង
ទៅ ។

នៃរ៉ាន់៖ ចុះកាលណឹងបើដូចថាគាត់ហៅ ទៅ លេងអ៊ំចង់នៅ ប៉ុន្មានថ្ងៃក៏បានដែរហ្អែស៎?

យឺម៖ ចង់នៅ ប៉ុន្មានក៏បានដែរ ។

នៃរ៉ាន់៖ អត់មានខាងឃុំអីណោះគេកំនត់ថាប៉ុណ្ណោះថ្ងៃៗទេ?

យឺម៖ អត់មានខាងឃុំប្តូទប់លេខ
១កំណត់ថានាងឯងទៅ លេងប្អូនកំណត់ប៉ុណ្ណោះថ្ងៃឲ្យមកវិញអត់មានទេ
ទៅប៉ុន្មានទៅចុះ ។

នៃរ៉ាន់៖ បាទ! ណឹងដោយសារប្អូនធ្វើធំដែរ...

យឺម៖ ណឹងឯង! គេដឹងថាប្អូនយើងធ្វើធំដែរណឹងណា៎ គេគោរពដែលណាស់ ។

នៃរ៉ាន់៖ អ៊ំទៅ លេងគាត់បានតែបីដងណឹងទេ?

យឺម៖ បីដងណឹងព្រាត់គ្នាទៅណាកូន... ។

នៃរ៉ាន់៖ ចុះពេលត្រឡប់មកវិញ?

យឺម៖ ត្រឡប់មកវិញមានបានប៉ុន្មានឆ្នាំបះបោរយ៉ាងម៉េចផ្ទៃក្នុង នៅផ្សារនៅខេត្តក្នុងទីក្រុង
ណឹង ។

នៃរ៉ាន់៖ ពេលអ៊ំត្រឡប់មកវិញអ៊ំទៅ លេងលើកទី ៣ ណឹងប្រហែលជាឆ្នាំណា?

យឺម៖ អត់ដឹងឆ្នាំណាទេ ។

នៃរ៉ាន់៖ អ៊ំត្រឡប់មកវិញបានប្រហែលរយៈពេលប៉ុន្មាន បានឮថាមានការបះបោរ?

យឺម: មានយូរប៉ុន្មានឮថាអូ..គេដឹកទាំងឡានៗយកទៅវ៉ៃចោលបះបោរក្នុងខេត្តក្នុងទីក្រុងគេយកទៅវ៉ៃចោល រយៈប្រហែលជាងកន្លះខែអីចោះ ។

នៃរ៉ាន់: បាទ! ចុះឮថាបះបោរណឹងខាងណាគេចុះមៅចាប់?

យឺម: អ៊ំអត់ដឹង ។

នៃរ៉ាន់: គេថាបះបោររឿងអី?

យឺម: អត់ដឹង អើគេថាយើងធ្វើធំ ។

នៃរ៉ាន់: ចុះអ៊ំឮពីណាមៅ?

យឺម: ឮពីគេពីឯងនិយាយដូចថាអ្នកស្រុអ្នកភូមិយើងគេដឹង គេថាអូ..ជានអីគេមិនចាប់ជាន់ធ្វើធំឲ្យតែអ្នកធំគេចាប់យកទៅសម្លាប់ចោលអស់ហើយមាំស្រុកតាខ្វែងតាអីណឹង ។

នៃរ៉ាន់: តាខ្វែងណឹងគេចាប់ដែរ?

យឺម: ចាប់ដែរដាក់ឡានទៅជាមួយគ្នាណឹងឯ..អោយតែអ្នកធំ ។

នៃរ៉ាន់: អ៊ំអត់ដឹងរឿងអីទេបានគេចាប់?

យឺម: អត់ដឹងរឿងអីទេកូន ។

នៃរ៉ាន់: ចុះមានឮថាប្រពន្ធគាត់គេចាប់ដែរអត់?

យឺម: អត់ទេប្រពន្ធអត់មានគេចាប់ទេ ប្រពន្ធទៅនៅស្រុកវិញ ។

នៃរ៉ាន់: សព្វថ្ងៃប្រពន្ធគាត់នៅឯណា?

យឺម: នៅពាមមុ្អីណោះ ។

នៃរ៉ាន់: នៅរស់ទេហ្អែស៎?

យឺម: នៅរស់ទេ ប៉ុន្តែដឹងគេសព្វថ្ងៃគេមានប្តីទៀតហើយក៏អត់ដឹងដែរណា៎ ព្រោះអីអ៊ំអត់ដែលបានទៅលេងទេ ។គេថាប្រពន្ធជាន់នៅណឹងឯងមានគេមៅនៅភូមិស្រុកជិតគ្នាណឹងហ្អាស៎គេថាប្រាប់ជងសុខសប្បាយទេ ប៉ុន្តែអត់លុយមៅលេងទេអីចេណាកូន ថាអត់លុយទៅលេងកូនលេងក្មួយទេ ។

នៃរ៉ាន់: បាទ! មិនដែលបានជួបគ្នាសោះ...?

យឺម: មិនដែលបានជួបទេ ។

នៃរ៉ាន់: ហើគាត់ក្រោយមៅមានកូនប៉ុន្មាននាក់?

យឺម៖ អេងណឹងហ្អែស…

នែវ៉ាន់៖ បាទ!

យឺម៖ អេងណឹងក្រោយមៅមានកូន ២ នាក់ហើយ កូនសុទ្ធស្រី ។

នែវ៉ាន់៖ សុទ្ធស្រីហ្អែស៎?

យឺម៖ ចា៎! ដល់ក្រោយមៅចាប់ប្ដីទៅថាកើតកូន ១ ទៀត ។

នែវ៉ាន់៖ បាទ!

យឺម៖ ខ្ញុំឮតែពីគេដែរណឹងណា ។

នែវ៉ាន់៖ បាទ!

យឺម៖ តែបើកូនស្រីមានតែកូនស្រី ២ កូនតែ ២ ណឹងហើយ ។

នែវ៉ាន់៖ អត់ដឹងឈ្មោះអីខ្លះ?

យឺម៖ អត់ដឹងឈ្មោះអីទេ ។

នែវ៉ាន់៖ អីចឹងកាលអ៊ំទៅលើកទី ៣ ណឹងកូនគាត់ទឹមបាន ១អាទិត្យទេ…?

យឺម៖ បាន ១ អាទិត្យទេ ។

នែវ៉ាន់៖ ហើយក្រោយមៅអត់បានទៅលេងទេ?

យឺម៖ ក្រោយមៅអត់ដែលបានទៅលេងទេ រហូតដល់វាបានកូន ១ ទៀត ដែលវាបកទៅមាកូន ១ ទៀតស្រី ។

នែវ៉ាន់៖ បាទ!

យឺម៖ ឮដំណឹងពីគេមៅពីព្រះម្ហូណឹងដែរដែរណា…គេមៅប្រាប់ខ្ញុំ…ខ្ញុំអត់ដឹងដែរទេ គេប្រាប់មីវ៉ាប្អូនបងឯងវាមានកូន១ទៀត បែកពីប្ដីទៅកូនក្រោយណឹងស្រីដែរ ។

នែវ៉ាន់៖ ចុះអ៊ំឮដំណឹងថាគេចាប់អេងណឹងដាក់ឡានទៅណឹងប្រហែលជាឆ្នាំណាដែរអ៊ំ?

យឺម៖ អត់ដឹងថាប្រហែលជាឆ្នាំណាអត់ដឹង ។

នែវ៉ាន់៖ ដូចថារយៈពេលប៉ុន្មានក្រោយមៅបានបែក?

យឺម៖ មិនដឹងប៉ុន្មានទេ ។

នែវ៉ាន់៖ ដូចថាឮដំណឹងហើយរយៈពេលប៉ុន្មានបានវៀតណាចូល?

យឹមៈ	មិនប៉ុន្មានទេកូន មិនបាន ១ ឆ្នាំទេប្រហែលជា ២ ខែ ៣ ខែ ណឹងឯងយួនចូលមោណឹង បណ្ដោយណឹង ។

នៃរ៉ាន់ៈ	បាទ! ខ្ទង់ ៧៨ អីហើយ...

យឹមៈ	ចា៎!ប្រហែលជាបណ្ណឹង...

នៃរ៉ាន់ៈ	តាំងពីណឹងមោបាត់ដំណឹងរហូត?

យឹមៈ	បាត់រហូត...

នៃរ៉ាន់ៈ	អ៊ំអត់មានដែលស៊ើបសួរគេទេ?

យឹមៈ	ស៊ើបសួរគេ គេអត់ដឹងអត់ស្គាល់ ។

នៃរ៉ាន់ៈ	តែដឹងតែគេចាប់ដាក់ឡាន...

យឹមៈ	ដឹងតែគេចាប់ដាក់ឡាន ចុះវាបាត់ឈឹងហើយគេចាប់ដាក់ឡានហើយ គេអ្នកនិយាយហ្នាស់ អ្នកស្រុកភូមិឯងណឹងចេះតែឮពីគេពីឯងមោវាអត់ដឹងទេកូន ។

នៃរ៉ាន់ៈ	អត់ចាំឈ្មោះទេ?

យឹមៈ	អត់ដឹងថាឮពីណាៗទេ ឮតែគេថាអូបង ដាន់ ណឹងគេចាប់ជាមួយ តាខ្វែងអីដាក់ឡានយក ទៅសម្លាប់ចោលអស់ហើយហើយ ។

នៃរ៉ាន់ៈ	ឮតែដំណឹងតែពីគេតៗគ្នាណឹងទៅ.?

យឹមៈ	ដឹងដំណឹងតែពីគេតៗណឹងណាអត់ដឹងច្បាស់លាស់ទេ ។

នៃរ៉ាន់ៈ	តាំងពីណឹងបាត់ឈឹងបណ្ដោយ?

យឹមៈ	បាត់ឈឹងទាល់តែកូនឯងមោណឹង ។

នៃរ៉ាន់ៈ	ចុះអ៊ំកាលសម័យខ្មែរក្រហមគេឲ្យអ៊ំធ្វើអីទៅ?

យឹមៈ	ខ្មែរក្រហមគេអត់ឲ្យអ៊ំធ្វើអីទេ គេឲ្យអ៊ំធ្វើចុងភៅ ។

នៃរ៉ាន់ៈ	អូ..!អ៊ំមានកូន ១ ទៀត?

យឹមៈ	មានកូនទី ២ អាបងទី ១ នោះវាធំបន្តិចហើយ អាទី ២ នោះវានៅតូចគេឲ្យអ៊ំនៅចុង ភៅ ។

នៃរ៉ាន់ៈ	អីចឹងកាលអ៊ំនៅកូនទី ២ ណឹងអ៊ំមានបានទៅលេងគាត់ដែរអត់?

យឹមៈ	អត់បានទៅលេងទេ..មានតែអាកូនទី ១ ណឹងទេ ។

នៃរ៉ាន់ៈ	កូនទី ១ បានៗទៅ ពេលអ៊ំទៅលេងគាត់ណឹង អ៊ំអត់ទាន់មានកូន ១ ទៀតទេហ្អស៎?

ឃីមៈ អត់ទាន់មាន ១ ទៀតទេ ។

នែរ៉ាន់ៈ ទៅ ៣ ដងណឹងអត់ទាន់មាន ១ ទៀតទេហ្អែស៎?

ឃីមៈ អត់ទាន់មានទេ ។

នែរ៉ាន់ៈ បាទ! ទាំង ៣ ដងណឹងអត់ទាន់មានទេហ្អែស៎?

ឃីមៈ អត់ទាន់មានទេ ។

នែរ៉ាន់ៈ បាទ!

ឃីមៈ អ៊ំមើអ៊ំមានកូនទី ២ អត់បានទៅ លេងទេរត់បែកបាក់គ្នាកាលណឹងនារតីចូលមៅ ។

នែរ៉ាន់ៈ អូ..បាទ! តែអ៊ំពេល ៧៥ ពេលរំដោះ ៧៥ នេះគេឲ្យមើលកូនខ្ចី..?

ឃីមៈ មើលកូនខ្ចីអី...អ៊ំកូនខ្ចីទៅពលកម្មមុខនឹងគេមិនរួចទេ

នៅពលកម្មក្រោយគេឲ្យអ៊ំនៅចុងភៅ ។

នែរ៉ាន់ៈ ចាំមើខ្ញុំសួរអ៊ំបញ្ជាក់ត្រង់នេះបន្តិច..អ៊ំទៅ លេងគាត់ណឹងមិន ៧៥ ដែរ..ហើយអ៊ំអត់ទាន់

មានកូនទេអីចឹងនែស៎?

ឃីមៈ មានតែកូនបង ១ ទេ ។

នែរ៉ាន់ៈ បាទ..ពេល ៧៥ ណឹងអ៊ំធ្វើអីទៅមុនមានកូនទី ២ ទៀតហ្អាស៎គេឲ្យធ្វើអី ។

ឃីមៈ ធ្វើចំការធ្វើស្រែ ។

នែរ៉ាន់ៈ ធ្វើចំការធ្វើស្រែ...

ឃីមៈ ស្ទូងស្រូវ ដាំសណ្តែកដាំពោត ។

នែរ៉ាន់ៈ កាលណឹងមានសហករណ៍ទេ?

ឃីមៈ សហករណ៍មាន ។

នែរ៉ាន់ៈ សហករណ៍គេនៅឯណាទៅ?

ឃីមៈ សហករណ៍នៅសង្កែវានៅខាងណោះពីភូមិកំពង់គល់ចាស់ណាកូន ។

នែរ៉ាន់ៈ បាទ! កាលណឹងអ៊ំនៅជុំគ្រួសារដែរ?

ឃីមៈ ជុំគ្រួសារ ។

នែរ៉ាន់ៈ អីចឹងគេហៅទៅ ធ្វើទំពណឹងក្រោយមៅគាត់មៅវិញ?

ឃីមៈ គ្រួសារអ៊ំណឹងហ្អែស៎?

នែរ៉ាន់ៈ បាទ!

ឃឹមៈ គ្រួសារអ៊ំអត់ដែលបានទៅទេ ព្រោះអីគាត់អ្នករោគគេអត់យកទេ ។

ណៃរ៉ន់ៈ គាត់អ្នករើសគេទៅ ?

ឃឹមៈ អត់ទេគេរើសគាត់ទៅហើយ តែមើលឃើញគាត់វាស្គមគាត់វារោគច្រើន ។

ណៃរ៉ន់ៈ អូ! រោគច្រើន...

ឃឹមៈ មានរោគក្នុងខ្លួនច្រើនគេអត់យកគាត់ទេគេឲ្យគាត់មកវិញ ក្រោយមកគេឲ្យគាត់នាំផ្លូវ
គាត់ភូមិសាស្ត្រព្រៃនេះទៅ អីណេះព្រៃនេះទៅអីណោះ ។ គេឲ្យគាត់នាំទ័ពបាន ១ អាទិត្យ
គាត់រត់មកវិញ គាត់ថាអូ...យាយអ៊ើយសុទ្ធតែរត់គ្រោះ តាភើយបញ្ឆោបណ្តោយ ។

ណៃរ៉ន់ៈ ពីណាគេបញ្ឆោ?

ឃឹមៈ តាភើយ ។

ណៃរ៉ន់ៈ តាភើយណឹងពីណាគេ?

ឃឹមៈ តាភើយណឹងមេទាហានធំ កូនឯងមិនដែលឮតាភើយទេ...

ណៃរ៉ន់ៈ អត់ដែល...ដឹងភើយ?

ឃឹមៈ ហ្នឹងហ្អើយ...កូនឯងអត់ដែលឮក្នុងរ៉ត់យូ៉ទេ?

ណៃរ៉ន់ៈ ដឹងភើយ...

ឃឹមៈ ដឹងភើយ...គេយកគាត់ទៅដូចថាគាត់ដឹងព្រៃដឹងអី ។

ណៃរ៉ន់ៈ មេខ្មែរក្រហមណឹងហ្អែស?

ឃឹមៈ មេខ្មែរក្រហម ។

ណៃរ៉ន់ៈ ៧៥ ណឹងហ្អែស?

ឃឹមៈ អត់ទេ ៧៦,៧៧ ហើយ ។

ណៃរ៉ន់ៈ ៧៦,៧៧ គេហៅគាត់ទៅ.?

ឃឹមៈ បាន ១ អាទិត្យគាត់រត់មកវិញ គាត់ថាអ៊ូ...អញផាប់ហើយមានតែរថក្រោះ ហើយ
បាញ់ពីង១...យប់គាត់រត់មកវិញ ។

ណៃរ៉ន់ៈ បាទ! ចុះអ៊ំធ្វើស្រែចំការនៅនេះដូចថាហូបចុកអីយ៉ាងម៉េដែរ?

ឃឹមៈ បានតែហូបចុកទេកូន ។

ណៃរ៉ន់ៈ បានបាយប្លុកបបរ?

ឃឹមៈ បានបាយអីសម័យនេះណាកូន. ។

ផែភាន់ៈ អត់ទេកាលសម័យខ្មែរក្រហមហ្អាស៎?

ឃឹមៈ បបរ ជំនាន់ខ្មែរក្រហមណាកូនកូនស៊ីបាយរួម អ៊ំមានកូនង៉ាអីចឹងគេឲ្យអ៊ំនៅចុងភៅមាន

ការដ្ឋានគេ ១ ដាំបាយស្លឲ្យគេ មនុស្ស ៥០,៦០,៧០ ណឹងណា ។

ផែភាន់ៈ បាទ!

ឃឹមៈ ដាំខ្ទះត្នោត ៣ កំប៉ុង ១០ មាក់ ។

ផែភាន់ៈ បាទ!

ឃឹមៈ បានស្រូវបានអង្ករមិនដឹងយកទៅណាអស់ទេ

ស៊ីបបរ..បានច្រើនស្រូវដាក់ឃ្លាំងប៉ុនៗណោះ

ពេញៗប៉ុនមិនដឹងបញ្ចេញស្រូវអង្ករទៅណាទេ អ៊ំអីស៊ីបបររហូតម៉ាចប់ចុងម៉ាចប់ដើម ។

ផែភាន់ៈ បាទ!

ឃឹមៈ អាខែច្រូតក៏ស៊ីបបរអាខែអត់ច្រូតក៏ស៊ីបបរ ដល់ម៉ៅខែនេះហើយ ខែ៦ខែ៧ខែ ៨ហើយ

ណាកូនបបរ ១០ នាក់ ៣កំប៉ុង ។

ផែភាន់ៈ បាទ!

ឃឹមៈ ខ្មែរក្រហម..នារតីណឹងមិនធម្មតាទេណាកូន ។

ផែភាន់ៈ អូ..!ណឹងនារតីចូលម៉ៅហើយបានបបរ?

ឃឹមៈ ហ្នឹងហ្អើយបបរខ្មែរក្រហមនារតីណឹង ។

ផែភាន់ៈ ចុះពេល ៧៥ ពេលខ្មែរក្រហមរំដោះណឹងដូចថាការងាររហូបចុកអី?

ឃឹមៈ ហូបចុកអីណាកូនមាគេបើកឲ្យ គេបើកដូចថាអង្ករប្រហុកអំបិល គេបើកចែកឲ្យយើង ។

ផែភាន់ៈ អូ..!ពេល ៧៥ ណឹង....

ឃឹមៈ យើងរំដោះចេញពីណោះម៉ៅណាស៎...

ផែភាន់ៈ រំដោះចេញពីណាម៉ៅ...រំដោះចេញពីព្រៃម៉ៅ?

ឃឹមៈ រំដោះចេកពីព្រៃម៉ៅណា៎. គេឲ្យម៉ៅនៅភូមិកំពង់គល់នេះណា ។

ផែភាន់ៈ អាណឹងពេល ៧៥ ខ្មែរក្រហមវ៉ៃចូល?

ឃឹមៈ ណឹងហ្អើយខ្មែរក្រហមណឹងហ្អស៎...ចុះយើង ៧៥ មិនរំដោះម៉ៅវិញ ។

ផែភាន់ៈ បាទ!

យឺម៖ រំដោះមៅវិញណឹងគេបើកអីៗឲ្យយើងស៊ី ។

នែវ៉ន់៖ អូ!ខ្មែរក្រហមបើកឲ្យ?

យឺម៖ ខ្មែរក្រហមអីយើងខាណោះ ។

នែវ៉ន់៖ អាណឹងនិយាយពេល ៧៩ ពេលវៀតណាមចូលទេហ្អី?

យឺម៖ ហ្នឹងហ្អើយ ។

នែវ៉ន់៖ កាលពេល ៧៥ ហ្អាស់..កាល៧៥ ដល់ ៧៩មិនសម័យខ្មែរក្រហមហ្អែស់អ៊ី?

យឺម៖ សម័យខ្មែរក្រហមអាពតដូចតែគ្នាហ្នឹងឯង ។

នែវ៉ន់៖ បាទ!ប៉ុន្តែអាឆ្នាំ ៧៥ ណឹងគេឲ្យអ៊ំធ្វើការងារអីទៅ?

យឺម៖ ធ្វើកាស្រែចំការ ។

នែវ៉ន់៖ ពេលណឹងហូបបាយរួម...?

យឺម៖ បាយរួម

អោយស៊ីក្នុងការដ្ឋានអត់ឲ្យស៊ីតាមផ្ទះទេដូចថាទៅស៊ីហ្នឹងទៅតុគ្រែអីចឹងទៅរួចមៅផ្ទះមៅ មិនឲ្យកាន់ម្នាក់ ១ កំប៉ុងអីយកទៅផ្ទះទេ ។

នែវ៉ន់៖ ចុះអណឹងគេមានសហករណ៍គេ..?

យឺម៖ មានសហករណ៍គេ...អីចឹងបានតែប្អូនណឹងហៅបងទៅមិនចង់ឲ្យបងមៅវិញទេ មៅមានអង្ករមៅក្តោបគ្រាន់ធ្វើបាយឲ្យក្មួយស៊ីកុំឲ្យក្មួយវាអត់ដាច់ពោះណាស់ បើបបរ ១០ នាក់ ៣ កំប៉ុងអីចឹង ។

នែវ៉ន់៖ អីចឹងគាត់ដឹងថានៅអីនេះពិបាកដែរអីចឹង?

យឺម៖ ដឹងពិបាកដែរ ចង់បានបងយកទៅអីណោះដល់វាព្រាត់គ្នាអីចឹងទៅណាកូន បើថានៅបានយូរបែបយកបងទៅណោះមិនដឹង ។

នែវ៉ន់៖ បាទ! ចុះអីចឹងនៅនេះហូបតែបបរទេអត់បានបាយទេអីចឹង?

យឺម៖ បបរអត់បានបាយទេកូន ពេលជំនាន់ខ្មែរក្រហមអាពតណា៎ ពេលនារតីវាចូលមៅវាក់ផ្តាច់បណ្តោយ ។

នែវ៉ន់៖ ប៉ុន្តែមុននារតីចូលមៅក៏បបរដែរ?

យឺម៖ បបរដែរ...នារតីចូលមៅរិតណាស់ទៀតហើយកាន់ក្តាប់ស្រូវធ្វើបានមិនដឹងយកទៅណា ។

នែវ៉ន់៖ ចុះអ៊ំមិននារតីចូលមៅ ៧៨ ពេលអ៊ំធ្វើស្រែអីណឹងការងារគេឲ្យធ្វើយ៉ាងម៉េចទៅ?

ឃឹមៈ ការងារគេកំណត់អ្នកឯងធ្វើ អ្នកឯងធ្វើឡេះឡោះគេមិនចែកអ្នកឯងស៊ីទេ ។

ផៃរ៉ាន់ៈ តែដូចថាគេកំណត់ម៉ោហិកតាប៉ុន្មានតោនៗអីទេ..?

ឃឹមៈ អត់មានកំណត់ទេ ដូចថាធ្វើទៅ ១ ហិកតា ២ ហិកតា ៥ ហិកតាអីចឹងទៅ កម្មករ ប៉ុន្មាន ១០,២០ នាក់អីចឹងទៅ ។ ឡូវទៅដាំដុះអីទៅបន្លែបន្កាអីពោតអី សណ្តែកអីនាំគ្នាបេះយកមៅរៃអីចឹងទៅ ។

ផៃរ៉ាន់ៈ បាទ!

ឃឹមៈ មិនដឹងយកទៅលក់អីណាអីណីទេស៊ីទៅ...យកទៅបាត់ទៅ ។

ផៃរ៉ាន់ៈ ចុះនៅហ្នឹងមានពួកប្រជាជនថ្មីគេជម្លៀសម៉ោដល់ណឹងដែរ?

ឃឹមៈ នៅអីណា...

ផៃរ៉ាន់ៈ នៅភូមិឃុំអ៊ំនេះអ្នាស៎មានពួក ១៧ មេសាពួកថ្មីម៉ោទេ?

ឃឹមៈ មាដូចជាខាងប៉ៃលិន ខាងស្រឡូកកួយ
ម៉ោនៅភូមិអ៊ំណឹងណា៎គេជម្លៀសទៅនៅភូមិកំពង់ គល់ចាស់ណឹងណា៎ ។

ផៃរ៉ាន់ៈ បាទ! ណឹងគេហៅប្រជាជនថ្មី?

ឃឹមៈ ចា៎! គេហៅអ្នកមូលដ្ឋានថ្មី អ៊ំគេហៅមូលដ្ឋានចាស់ ។

ផៃរ៉ាន់ៈ អូ! គេចែកអីចឹងហ្អែស៎?

ឃឹមៈ គេចែកអីចឹង ។

ផៃរ៉ាន់ៈ ចុះដូចការងារមូលដ្ឋានថ្មីហើយ និងមូលដ្ឋានចាស់ណឹងដូចគ្នាដែរអត់?

ឃឹមៈ ដូចគ្នាស៊ីដូចគ្នាធ្វើការដូចគ្នា ។

ផៃរ៉ាន់ៈ អីចឹង!

ឃឹមៈ អ្នកឯងឈឺគ្រេតគ្រតអីមិនអាចចែករបបឲ្យទេ មិនថាចាស់មិនថាថ្មី ។

**«ចប់កាសែតទី១ ចំនួន ៣៨ ទំព័រ»**

ផៃរ៉ាន់ៈ អីចឹងអ្នកមូលដ្ឋានថ្មី និងមូលដ្ឋាចាស់ណឹងធ្វើការងារដូចគ្នា?

យឺម៖ ចាំ! ដូចគ្នាក្រោយមោះពេលយើងមានមាសប្រាក់អីបន្តិចបន្តួចអីចឹងណាកូនមេសហករណ៍គេណាកូន...។

នែរ៉ន់៖ មេសហករណ៍គេឈ្មោះអី?

យឺម៖ មិនដឹងឈ្មោះអីទេ ទៅណាមោះណីទេ...

នែរ៉ន់៖ មិនមែលអ្នកស្រុកកំពង់គល់យើងណឹងទេ?

យឺម៖ ទេមិនមែនអ្នកស្រុកណឹងទេ។

នែរ៉ន់៖ មោះពីណាផ្សេង?

យឺម៖ មិនដឹងមោះពីណាផង

សហករណ៍មិននៅជិតណឹងផងព្ទតែសហករណ៍សង្កែវាៗគេទៅ នៅគេ

ទៅ នៅភូមិចាស់កំពង់គល់អីណោះ អឺមិនដែលឃើញសហករណ៍គេណឹងវាម៉េច។

នែរ៉ន់៖ អីចឹងពេលអឺ ទៅហូបបាយអត់ទៅហូបនៅសហករណ៍ណឹងទេ?

យឺម៖ អត់ទេនៅតាមភូមិរយើងណឹងហ្នាស់ សហករណ៍គេនៅ ផ្សេងនៅតាមភូមិអីចឹងដូចថាមេភូមិគេ មេខ្នងគេនោះមាការដ្ឋាន ១ ទៅមានអ្នកកាន់ក្តាប់មួយទៅ មិនមែនទៅច្របូកជាមួយសហករណ៍គេទេ។

នែរ៉ន់៖ ចុះដូចថាប្រជាជនថ្មី

អ្នកមូលដ្ឋានថ្មីអ្នកមូលដ្ឋានចាស់ដូចថាអ្នកមូលដ្ឋាថ្មីណឹងគេតាមដានតឹង

រឹងជាប្ញក៏យ៉ាងម៉េច?

យឺម៖ តឹងរឹង គេឲ្យអ្នកមូលដ្ឋានចាស់តាមដានអ្នកមូលដ្ឋានថ្មីតឹងរឹងទៅខ្លាចវាលួចស្អីយកទៅស៊ីដាំ ស៊ីក្នុងផ្ទះ។

នែរ៉ន់៖ អូ..!គេប្រាប់អីចឹង។

យឺម៖ ប្រាប់អ្វីចឹង។

នែរ៉ន់៖ ពីណាអ្នកប្រាប់អីចឹង។

យឺម៖ ចុះមេកងគេ។

នែរ៉ន់៖ ឈ្មោះអីទៅ?

យឺម៖ ឈ្មោះឡាប។

នែរ៉ន់៖ អ្នកស្រុកភូមិគល់ណឹង?

យឹម: ចាំ! មិនឲ្យនិយាយថាសម្លាប់ ។

នែរ៉ាន់: អូ!គាត់ហាមមិនឲ្យនិយាយទេ?

យឹម: ហាមមិនឲ្យនិយាយទេអានឹងខាងនារតីណា...

នែរ៉ាន់: អូ!អាណឹងពេញនារតីហើយ...?

យឹម: ពេញនារតីហើយ ។

នែរ៉ាន់: ចុះមិនណឹងហ្នាស់?

យឹម: មុនណឹងក៏ដោយ ។

នែរ៉ាន់: ចុះហូបចុកគេឲ្យហូបប៉ុន្មានពេល?

យឹម: ២ ពេលព្រឹកល្ងាច បបររាវ ។

នែរ៉ា: ថ្ងៃត្រង់អត់មានទេ?

យឹម: អត់មានហូបថ្ងៃត្រង់ទេ ហើយព្រឹកហូបម៉ោង ១០ ម៉ោង ១១អីណឹង ។

នែរ៉ាន់: ហីល្ងាចហូបម៉ោងប៉ុន្មាន?

យឹម: ហូបម៉ោ ៤ អីណឹង ។

នែរ៉ាន់: ហូបឆ្អែតទាំងបន្លែ...ចុះបើ ១០ នាក់ ៣ កំប៉ុងនោះរាវៗកក្កូក ។

យឹម: បាទ!

នែរ៉ាន់: ចុះមានម្ហូបទេ?

យឹម: ថ្ងៃណាមានម្ហូបមានទៅ ថ្ងៃណាអត់អត់ទៅ ។

នែរ៉ាន់: ចុះយប់អីគេឲ្យធ្វើការទេអ៊ំ?

យឹម: យប់ធ្វើគេឲ្យធ្វើ ។

នែរ៉ាន់: ធ្វើដល់ម៉ោងប៉ុន្មានទៅ?

យឹម: គេនៅកម្លាំងមុខគេធ្វើទៅអ៊ំអីនៅកម្លាំងក្រោយអត់ធ្វើទេធ្វើពីម៉ោង ៦,៧ទៅដល់ម៉ោ ១០ សំរាក ។

នែរ៉ាន់: បាទ! ដូចថានៅក្រោមអីណោះពិបាកអីចឹង..ប្អូនអីគាត់ដឹងទេ?

យឹម: ដឹងថាពិបាកដែរចង់បានបងយកទៅអីណោះ
បង..ចាប្រូតកាត់រូប..ប្រូតកាត់រូបបងប្អូនបែក បាក់អីចឹង ។

នែរ៉ាន់: ចុះអ៊ំមានសួរគាត់ទេថាខាងក្រោមនេះពិបាកហើយខាលើអីណោះស្រួល?

យឹមៈ ដូចថាទៅ អីចឹងទៅ ប្ដីរបស់អ៊ំណើងគាត់ចូលធ្វើការជាមួយទៅ
ចូលធ្វើការជាមួយប្អូនទៅមាន ឈ្មោះទៅ ។

ឆៃវ៉ាន់ៈ បាទ!

យឹមៈ ដូចថាមានឈ្មោះធ្វើការទៅ អ៊ំណើងនៅជាមួយទៅ ។

ឆៃវ៉ាន់ៈ អ៊ំ ឃើញអីចឹងហ្អែស៎?

យឹមៈ អ៊ំ ឃើញអីចឹង ។

ឆៃវ៉ាន់ៈ ចុះដូចថាអ៊ំ ធ្លាប់ទៅ លេងគាត់អីចឹងហ្អាស៎
ដូចថាអ៊ំ នៅក្នុងភូមិនេះហូបបបរពិបាកអីចឹងណាស៎
ទៅដល់ណោះគាត់ហូបបាយមានម្ហូបអីបប្វូរ...

យឹមៈ អូ...!បាយម្ហូបអីបប្វូរ ។

ឆៃវ៉ាន់ៈ អ៊ំមានដែលសួរគាត់ថាម៉េចបាននៅកន្លែងគាត់ធ្វើការណើងស្រួល ហើយអីនេះពិបាកទេ?

យឹមៈ អ៊ំអត់ដែលមានសួរទេ បើប្អូនសួរបង ។

ឆៃវ៉ាន់ៈ សួរថាម៉េច?

យឹមៈ មានអីហូបសព្វថ្ងៃនោះបងហូបបបរឬក៏ហូបបាយ..ថាអូនអើយបងហូបបបររាល់ថ្ងៃ
ហូបបបររាល់ថ្ងៃអាណិតក្លួយខ្ញុំអាណិតបងខ្ញុំណាស់ ។ អីចឹងខ្ញុំចង់ឲ្យបងដេកលេង៨,១០
យប់ អីចឹងណា៎កូន អីចឹងខ្ញុំថាអ៊ំថា ៨,១០ យប់មិនអាចបានទេអូន ទៅដំបូងកូន...បាន
៥យប់មៅវិញ ចាំបងមៅលេងទៀត ។ ក្រោយមៅប្អូនឲ្យទៅ លេងទៀត ។
ទៅ លេងទៀត ធ្វើចំណីឲ្យបងឲ្យបងជួយធ្វើ...ថាបងយើងធ្វើនំបញ្ចុក
គេទៅ គេធ្វើនៅ អីណោះអស់ហើយ ។

ឆៃវ៉ាន់ៈ ចុះគាត់ដឹងថានៅភូមិនេះបានតែបបរដែរ?

យឹមៈ ដឹង...ដឹងតែពីអ៊ំ ទៅណើងណា៎ ។

ឆៃវ៉ាន់ៈ គាត់អត់មានសួរថា ម៉េចក៏បានតែបបរអីចឹងទេ?

យឹមៈ សួរដែរថា ម៉េចបានគេឲ្យតែបបរអត់មានបាយធ្វើស្រូវអត់បាហ្អ៎...ថាទេអូនយើងធ្វើស្រូវ
បាន ។ បងឯងអីទៅ ធ្វើកម្លាំងមុខស្រូវទាំងឃ្លាំងៗប៉ុន្តែអត់ដឹងថាគេដឹកទៅឃ្លាំងណា
ហើយ ឃើញស៊ីបបរខ្វះប្រាំងខ្វះវស្សា ។

បើយើងនៅខ្មែរក្រហមនៅឡើយយើងពេលខែច្រូតអី ណឹងដូចថាខែ

៥ខែអីណឹងហូបបាយហើយណា៎ ខែ ៦, ខែ៧, ខែ៨, ណឹងស៊ីបបរ ហើយ ។

នៃរ៉ាន់ៈ ណឹងពេលខ្មែរក្រហមហ្មែ៎?

ឃីមៈ ខ្មែរក្រហមចូលនារតី ។

នៃរ៉ាន់ៈ អីចឹងមានពេលបាយមានពេលបបរហ្មែស៎?

ឃីមៈ ដល់ពេលនារតីចូលបបររហូត ពេលច្រូតក៏បបរអស់ច្រូតក៏បបរដែរ ។

នៃរ៉ាន់ៈ នារតីគេចូលមៅពីឆ្នាំណា?

ឃីមៈ ប្រហែលឆ្នាំណាខ្ញុំអត់ដឹងទេ ។

នៃរ៉ាន់ៈ ពេលដែលនារតីចូលមៅនឹងត្រូវដំណឹងថាចាប់ប្អូនណឹង?

ឃីមៈ ពេលនារតីចូលមៅអត់ទាន់ត្រូទេ ក្រោយមៅទៀតបានត្រូដំណឹងថាចាប់ប្អូន ។

នៃរ៉ាន់ៈ អីចឹងត្រូថាចាប់ប្អូនពេលនារតីចូលមៅ?

ឃីមៈ ចា៎!

នៃរ៉ាន់ៈ នារតីចូលមៅប្រហែលជាប៉ុន្មានឆ្នាំ?

ឃីមៈ មិនប៉ុន្មានទេ យ៉ាងច្រើន ៣,៤ខែណឹង ។

នៃរ៉ាន់ៈ ចូលបានបន្តិច វៀតណាមចូលមៅ...?

ឃីមៈ ណឹងហ្អើយ ។

នៃរ៉ាន់ៈ អីចឹងអ៊ំហូបបបរបានតែមួយខែ?

ឃីមៈ ណឹងហ្អើយដែអ៊ំរត់ទៅអីណោះទៀត ទៅដល់រតនមណ្ឌលយើងនេះណាកូន

អ៊ំមានតែខ្លួនទទេ វាសម្លុតឲ្យចោលអីវ៉ាន់អស់ ។

ទម្លាក់ចោកអស់កំពង់ថ្ងៃស្ពានណឹងហ្អែកអ៊ំកំពង់ហាលស្រូវ ហ្អាស៎

ទៅយកស្បៀងនឹងគេដែលយើងចេញពីនេះដែលវាបំរុងឲ្យចេញទៅអត់ស្បៀង ទៀត ។

នៃរ៉ាន់ៈ ដល់ ៧៩ វៀតណាមចូលមៅគេគៀយើងទៅទៀតហ្អែស៎?

ឃីមៈ ហ្នឹងហ្អើយវាគៀទៅទៀតណាស៎ ។

នៃរ៉ាន់ៈ តាំងមុននារតីចូលមៅណឹងប្រហែលរយៈពេលប៉ុន្មានមិនវៀតណាមចូល?

ឃីមៈ ប្រហែល ១ ខែអីណឹង គេថាឲ្យទៅយកស្បៀងៗ ។

នៃរ៉ាន់ៈ រយៈពេលខ្លីដែរហ្អែស៎?

ឃឹមៈ ណឹងហ្អើយរយៈពេលខ្វីដែរប្រហែល ១ ខែ ១ខែជាង អីចឹងគេថាអស់ស្បៀងទៅយកស្បៀង គេហៅអណ្ដើកហែបៗណឹង ។ អ៊ំប្រុសឯងណឹងទៅយកគាត់លីបានស្រូវកន្ទះបាវណឹង គាត់លីមៅណឹងណាកូនគាត់លីមៅមាក្របួចបាវធំណឹង..បាវ ១០០គីឡូណឹងកូន ។ គាត់លីមៅអ៊ំដាក់ហាល ដាក់ហាលស្រាប់តែឃើញយួនមៅម៉ាសន្ទុះ ស្រាប់តែពុ្របាញ់ភឹងៗ អូនារតីមៅទៀតហើយ ។ គ្រាន់តែថានារតីមៅដល់បាញ់អ៊ំប្រាវមុខអ៊ំទម្លាក់ចោលៗកូន ហ្អើយមនុស្សរាប់រយរាប់ពាន់ ចោលអស់បញ្ឈាឲ្យទៅលិចខ្វាចយួនមៅទាន់ ។

នែរ៉ាន់ៈ បាទ! ប៉ុនអ៊ំពេលយួនមៅមេភូមិមេឃុំអីគេមានបួទេ?

ឃឹមៈ អត់មានបួរទេ បួរមិនទាន់ទេវាចលាចល់...

នែរ៉ាន់ៈ អីចឹងដូចថានៅនេះមេភូមិនៅនេះឈ្មោះអីដែរ?

ឃឹមៈ សព្វថ្ងៃនេះ?

នែរ៉ាន់ៈ អត់ទេកាលជំនាន់ខ្មែរក្រហម?

ឃឹមៈ កាលជំនាន់លខ្មែរក្រហមមេភូមិឈ្មោះឡាប ។

នែរ៉ាន់ៈ តាឡាប...ចុះមេឃុំ?

ឃឹមៈ អត់មានមេឃុំផង ។

នែរ៉ាន់ៈ មានតែតាឡាបណឹងធំជាងគេ?

ឃឹមៈ តាឡាបណឹងសហករណ៍ ។

នែរ៉ាន់ៈ មេសហករណ៍...

ឃឹមៈ មិនមេទេក្រោមវងគេទេ អត់មានមេទេ ។

នែរ៉ាន់ៈ ចុះមេតាឡាបណឹងពីណាគេ?

ឃឹមៈ ឈ្មោះ យ៉ាន់ ។

នែរ៉ាន់ៈ យ៉ាន់ណឹងស្រីឬប្រុស?

ឃឹមៈ ប្រុស ។

នែរ៉ាន់ៈ គាត់អ្នកស្រុណា?

ឃឹមៈ នៅស្រុកថ្មព្រួស ។

នែរ៉ាន់ៈ បាទ!នៅបាត់ដំបងណឹងដែរហ្អែស៎?

យឹម៖ នៅ បាត់ដំបងណាង ។

នៃវ៉ាន់៖ រាល់ថ្ងៃនៅរស់ទេ?

យឹម៖ ឈ្មោះយ៉ាន់អីចឹងហ្អែស៎ ។

នៃវ៉ាន់៖ ចុះបន្ទាប់មោ៉ទៀតពីណាទៀត?

យឹម៖ ឈ្មោះតាភូតមួយ ។

នៃវ៉ាន់៖ តាភូតណឹងនៅក្នុងសហករណ៍គេណឹងដែរហ្អែស៎?

យឹម៖ ហ្នឹងហើ្អយ ។

នៃវ៉ាន់៖ ចុះគណៈស្រុកគេឈ្មោះអី?

យឹម៖ អត់ដឹងទេ គណៈស្រុកគេអត់ដឹងឈ្មោះអីទេ ។

នៃវ៉ាន់៖ ឃុំអត់ដឹងដែរ?

យឹម៖ អត់ដឹងទេ ។

នៃវ៉ាន់៖ ហ្នឹងកាលជំនាន់ខ្មែរក្រហមគេហៅស្រុកលេខប៉ុន្មានដែរ?

យឹម៖ អុំអត់បានដឹងថាស្រុកលេខប៉ុន្មានផង ។

នៃវ៉ាន់៖ ចុះតំបន់?

យឹម៖ អត់ដឹងថាតំបន់លេខប៉ុន្មានផង ។

នៃវ៉ាន់៖ ចុះដូចថានៅសម័យណឹងដូចថាធ្លាប់ឃើញគេចាប់មនុស្សយកទៅសម្លាប់ទេ?

យឹម៖ ឃើញជំនាន់ខ្មែក្រហមណឹង ឃើញសម្លាប់មនុស្សច្រើនណាស់កូន ។

នៃវ៉ាន់៖ អុំឃើញផ្ទាល់ភ្នែកហ្អែស៎?

យឹម៖ ផ្ទាល់ភ្នែកសម្លាប់ក្រោមផ្ទះឪពុកធំអុំណឹង គាត់ធ្វើមេភូមិ..ជំទប់លេខ ១ ។

នៃវ៉ាន់៖ ជំទប់ពីដើមគេហៅមេឃុំហ្អែ៎?

យឹម៖ ជំទប់,ស្មៀន,ជំទប់លេខ ១ ។

នៃវ៉ាន់៖ ណឹងគាត់ជំទប់លេខ ១ ជំនាន់ខ្មែរក្រហម?

យឹម៖ ជំនាន់សម្តេច ។

នៃវ៉ាន់៖ អូ!ពីសម្តេចមោ៉..ដល់ពេលខ្មែរក្រហមចូលមោ៉ ៧៥ ណឹង...

យឹម៖ ៧៥ គេទម្លាក់អស់ហើយកូន...

នៃវ៉ាន់៖ ហើយគេចាប់គាត់សម្លាប់?

យឹមៈ ចាប់សម្លាប់ ។

ផៃរ៉ាន់ៈ សម្លាប់នៅអីណាទៅ ?

យឹមៈ សម្លាប់នៅភូមិបវេល ។

ផៃរ៉ាន់ៈ អាណឹង ៧៥ ណឹងហ្អែស៎?

យឹមៈ ៧៥អីអត់ទេសម្លាប់មុនណឹងទៀត ។

ផៃរ៉ាន់ៈ មុន ៧៥ ...

យឹមៈ អើ! ៧៤,៧៣ រត់ទៅលើណាកូន ។

ផៃរ៉ាន់ៈ បាទ!

យឹមៈ គេថាមេឃុំណឹងអត់ឈ្មោះត្រង់ ។

ផៃរ៉ាន់ៈ អូ...អាណឹងជំនាន់លន់ណុលទេហ្អែស៎?

យឹមៈ ជំនាន់លន់ណុល ។

ផៃរ៉ាន់ៈ អីចឹងនៅភូមិនេះខ្មែរក្រហមចូលមៅកាន់តាំងជំនាន់លន់ ណុល អីណោះ
អត់មានលន់ណុល ចូលមៅទេ?

យឹមៈ អត់លន់ ណុល ចូលមៅទេ ។

ផៃរ៉ាន់ៈ ចុះពេល ៧៥ ដល់ ៧៩ អ៊ំដែលឃើញគេសម្លាប់មនុស្សទេ ពេលដែលខ្មែរក្រហមរំដោះ
បានទាំងអស់ហ្អាស៎?

យឹមៈ សម្លាប់ឃើញ ។

ផៃរ៉ាន់ៈ ឃើញនៅឯណាទៅអ៊ំ?

យឹមៈ ឃើញនៅភូមិអ៊ំណឹង គេយកមៅក្រោមផ្ទះរគេរគាយ ដៃជើងជាប់គ្នាទាំងខ្សែៗណាកូន ។

ផៃរ៉ាន់ៈ បាទ!

យឹមៈ ដើរទៅដាក់ភូសបែកឈាមណាកូន អ៊ំឃើញភ្នែកអ៊ំណាកូនមិនធម្មតាទេស្លូវបួនខ្ញុំនោះ ។

ផៃរ៉ាន់ៈ អីចឹងពេលដែលគេចាប់មៅណឹងពួកមូលដ្ឋានចាស់ឬមូលដ្ឋាថ្មី?

យឹមៈ ដូចថាមូលដ្ឋានចាស់អ្នកគំនិតអាក្រក់...គ្នាល្អថាគ្នាអាក្រក់ ។

ផៃរ៉ាន់ៈ អូ.!

ឃឹមៈ ថាគ្នាចូលដៃចូលជើងខាងក្នុងជំនាន់សម្តេចហើយថាគ្នាចូលខាងលន់ ណុល ថាគ្នាចូលខាងខ្មែរក្រហម វ៉ៃគ្នាទៅគ្នាមិនដឹងឆ្លើយថា... ។

នែរ៉ាន់ៈ ហ្នឹង ៧៥ ហើយណឹងហ្អែស៎?

ឃឹមៈ អត់ទេមុន ៧៥ តាំងឆ្នាំ ៦៨អីណោះណា៎ ។

នែរ៉ាន់ៈ អាឃើញគេបណ្តើរចងមៅ៉ណឹងហ្អាស៎?

ឃឹមៈ ណឹងហ្អើយមុន ៧៥ ណាកូនអុំអត់ទាន់រត់ទេណា៎ ។

នែរ៉ាន់ៈ មុនខ្មែរក្រហមរំដោះប្រទេសជាតិណឹងទៅទៀត អុំយ៉េត្នប្រឡុំអាមួយវៀតណាមចូលអាមួយខ្មែរក្រហមចូល?

ឃឹមៈ អត់ទេអុំអត់ទាន់រត់ទៅព្រៃទេ វ៉ៃចងខ្សែជក់ដួង ។

នែរ៉ាន់ៈ បាទ!

ឃឹមៈ ចងម៉ាជួរៗតាមណឹងផ្ទះអុំ ក្រោមផ្ទះអុំណឹងបណ្តោយណឹងណា៎ ។

នែរ៉ាន់ៈ អីចឹងតាំងមុន ៧៥ ណឹងមានគេចាប់មនុស្សចាប់អីដែរ?

ឃឹមៈ ចាប់...ឪពុកក្មេកអុំធ្វើជំទប់លេខ ១ គេចាប់ចងនៅផ្ទះជំទប់លេខ ១ ណឹងឯង ។

នែរ៉ាន់ៈ គេចាប់ពួកមន្ត្រីចាស់ អីចឹងពួកដែលចាប់មៅ៉ណឹងសុទ្ធតែមន្ត្រីចាស់?

ឃឹមៈ មន្ត្រីចាស់អីគ្នាមនុស្សល្អថាគ្នាគំនិតអាក្រក់
គ្នាមិនឆ្លើយវ៉ៃឲ្យគ្នាឆ្លើយទៀតមែនឬមិនមែន... គ្នាឆ្លើយថាមិនមែនទេ..ថស
អីចឹងណាកូន ។

នែរ៉ាន់ៈ អុំឃើញដែរ?

ឃឹមៈ អុំឃេញផ្ទាល់ភ្នែកអុំញ័រអីចេះកូន...អុំនៅលើផ្ទះអុំអត់ហ៊ានចុះទេណាកូន
ប៉ុន្តែអត់មានបាញ់ ទេមានតែវ៉ៃណឹង
ស្បែកជើងគេណឹងគេហៅអំប្រ៉ង់ម៉េច...លើកជើងធាក់អីចឹង ។

នែរ៉ាន់ៈ ណឹងពួកខ្មែរក្រហមគេចាប់បាន?

ឃឹមៈ ណឹងហ្អើយ ។

នែរ៉ាន់ៈ ចុះពេល ៧៥ ពេលខ្មែរក្រហមរំដោះប្រទេសបានទាំងមូលហ្អាស៎អុំ ...អុំមានដែលឃើញគេចាប់មនុស្សដែរអត់?

យឺម៖ អត់ដែលឃើញទេ ។

នៃរ៉ាន់៖ អាណឹងអត់ដេលទេ...៧៥ ,៧៦អីណឹងហ្អាស់?

យឺម៖ អត់ដែលឃើញទេ ។

នៃរ៉ាន់៖ ចុះប្រជាជនមូលដ្ឋាថ្មីដែលជម្លៀសមៅ៉នៅ នេះរហូតឬក៏ផ្លាស់ទៅណាទៀត?

យឺម៖ ជម្លៀសទៅ ..អីចឹងបានថាបែកបាក់គ្នាដែលរំដោះគៀយកទៅ ។

នៃរ៉ាន់៖ ដល់ពេល ៧៩ ណឹងប្រជាជនថ្មីណឹងគេរត់បែកខ្ញែកគ្នាទេហ្អែស់?

យឺម៖ បែកខ្ញែកគ្នាទេ ។

នៃរ៉ាន់៖ បាទ!ពេលដែលគេគៀពីណាពីណីមៅ៉នៅក្នុងពេល ៧៥ ណឹង ដូចថាគេអត់មានជម្លៀសតទៅណាទេ?

យឺម៖ អត់មានជម្លៀសតទៅណាគេ វាបែកគ្នាបណ្តោយ ។

នៃរ៉ាន់៖ អូ!អីចឹងពីចន្លោះ ៧៥ មៅ៉ណឹងដូចថាអត់មានឃើញសម្លាប់មនុស្ស?

យឺម៖ អត់ ។

នៃរ៉ាន់៖ អត់ដែលឃើញទេ?

យឺម៖ អត់ដែលឃើញទេ ប៉ុន្តែ ៧៥ ណឹងមានរំដោះមៅ៉ពីលើអីងមៅ៉មានដូចថាមេខ្នងគេ ហើយមសហករណ៍គេណឹងដូចថាកូនឯងធំជាងអ៊ំកូនសហករណ៍គេអីចឹងទៅ អាណឹងឯងអាតពីអ៊ំណឹងចេកចុចគ្នាស៊ីបាយយកម្ទេស ១ គ្រាប់ថាគ្នាធ្វើចោរលួចរបស់គេវ៉ៃគ្នា ។

នៃរ៉ាន់៖ ពេល ៧៥ ណឹង?

យឺម៖ ណឹងហ្អើយ!

នៃរ៉ាន់៖ អ៊ំធ្លាប់ឃើញគេវ៉ៃ?

យឺម៖ ធ្លាប់ឃើញគេវ៉ៃ ។

នៃរ៉ាន់៖ គេចោទថាម៉េច?

យឺម៖ គេចោទថាឃើងចោរលួចបេះម្ទេសគេកាច់មែកម្ទេស អ៊ំឃើញ
នឹងភ្នែកអ៊ំណាកូនអ៊ំមិនយក
ភ្នែកគេមើលទេ ។កាច់មែកម្ទេសចងបាច់ៗនៅខ្នងគេចងដូចសាក់កាដូរ អីចឹងទៅរួចគេចងដៃទៅក្រោយ ហើយឲ្យបណ្តើរគ្នាដើរទៅវ៉ៃផស..អាណឹងចុង ៧៥ ចូល ៧៦ ហើយ

កូន ។ អីចឹងចាប់គ្នាពីរនាក់អីចឹងបោះលើរទេះគោ បោះភូសព្ទអៀកអីចឹងទៅយកគ្នាទៅសម្លាប់ទៅ ។

ផៃរ៉ាន់: អូ! គ្រាន់តែបេះម្ទេសសោះ...

ឃីមៈ ហ្នឹងហើយគ្រាន់តែម្ទេសយកមៅស៊ីណឹងណា ។

ផៃរ៉ាន់: អ្នកដែលគេចាប់ទៅណឹងអ៊ំស្គាល់ឈ្មោះទេ?

ឃីមៈ អ្នកថ្មី មៅនៅជិតអ៊ំណឹងបានអ៊ំដឹងឈ្មោះគាត់តាសាង១

គាត់រកអីស៊ីគ្មានទេអ៊ំ នៅជិតខាង អីចឹងគេបើកប្រហុក បើកអំបិល បើកអង្ករអីអោយដូចថាអ៊ំកូន ១ ម៉ែ ១ ប្ដីអ៊ំទៅស៊ីក ម្ញាំងមុខអីណោះ

អ៊ំមានតែម៉ែមួយកូនមួយបានអង្ករមួយតៅ ជៅតអីចឹងទៅ ។អ៊ំសំចៃទុកឲ្យ កូនទៅ អ៊ំហូបសំចៃទុកឲ្យកូនទៅ អ៊ំហូបបបររាវ១ កាលណឹងអ៊ំមានកូនមួយណាកូន ។

ផៃរ៉ាន់: ចុះកាលណឹងគេគេបើអង្ករឲ្យដែរហ្អេស៎?

ឃីមៈ គេបើកឲ្យដែរ ។

ផៃរ៉ាន់: បើកឲ្យតែពួកមូលដ្ឋានចាស់ទេ..ថ្មីអត់ទេ?

ឃីមៈ ថ្មីកំណត់ឲ្យទៀត ហើយធ្វើការកុំឲ្យរគេតរតូតហីឲ្យទៅកាប់ពោតអីដូចថាពោតត្រង់ណឹងចាស់ហើយ តិចថាកាប់ដាក់មូហោជៅ១,២ អីអត់បានទេ ។

ផៃរ៉ាន់: អីចឹងពួកអ្នកថ្មីហើយនឹងអ្នកចាស់..ពួកអ្នកថ្មីពិបាកជាង?

ឃីមៈ ពិបាកជាង ។

ផៃរ៉ាន់: គេចែកអង្ករឲ្យពួកអ្នកចាស់ណឹងរហូតដល់ឆ្នាំណាបានគេឈប់ចែក?

ឃីមៈ អ្នកចាស់ណឹងចែកចុង ៧៥ ណឹងឯងក្រោយមៅគេឲ្យហូបរួម គេអត់ឲ្យទៀតទេ ។

ផៃរ៉ាន់: បាទ! អ៊ំឃើញអ្នកប្រជាជនថ្មីណឹងគេចាប់ច្រើនទេ?

ឃីមៈ ទេឃើញគេចាប់ទៅសម្លាប់ពីរនាក់ ។

ផៃរ៉ាន់: ឈ្មោះអិខ្លះ?

ឃីមៈ ១ ឈ្មោះ សាង ,មួយទៀតឈ្មោះតាដៃ គាត់មៅពីស្រុកបាសាងនៅអីលើគេរំដោះមៅណឹងណា៎ ។

ផៃរ៉ាន់: បាទ!

យឹមៈ ពួក ប៉ុសាង,ពួកបរ ម៉ោណឹងគេរំដោះម៉ោណឹង ។

ឆៃវ៉ាន់ៈ បរអីបរកែវ...?

យឹមៈ បរប៉ៃលិន..រំដោះម៉ោនៅភូមិកំពង់គល់អ៊ំណឹងណាស់ ។

ឆៃវ៉ាន់ៈ បាទ!

យឹមៈ ម៉ោនៅឆ្នូកជាមួយ នឹងរំដោះចាស់ណឹងគេហៅមូលដ្ឋានចាស់ មូលដ្ឋានថ្មី ។

ឆៃវ៉ាន់ៈ គេឲ្យនៅឡូកឡំជាមួយគ្នាដែរ?

យឹមៈ ឲ្យនៅឡូកឡំជាមួយគ្នាអីចឹងណា.. ។

ឆៃវ៉ាន់ៈ អីចឹងដូចតាសាងណឹងគាត់ខុសរឿងបេះម្ទេស?

យឹមៈ គាត់ខុសបេះម្ទេសគេចាប់បាច់ម្ទេសចងពីបីមែកណាស់ កាច់យកម៉ោស៊ីផ្ទះគ្រាប់តែមួយ
ពេលម៉ាគ្រាប់ណឹងណាកូនគាត់ម៉ោបីពលកម្មណាំ ។ដល់អីចឹងគេចាប់កាច់បាច់បណ្ដោះម៉ោគេ
ចងនៅខ្នងទៅ គេវ៉ៃទៅ
គេចងខ្សែដៃអីចេះទៅ គេវ៉ៃទៅដល់ពេលនេះគេចាប់បោះលើរទេះ
ក្តុកទៅយកទៅបណ្ដោយ ។

ឆៃវ៉ាន់ៈ យកទៅណាទៅអ៊ំ?

យឹមៈ យកទៅសម្លាប់ ។

ឆៃវ៉ាន់ៈ សម្លាប់អីណាទៅអ៊ំ?

យឹមៈ សម្លាប់នៅក្នុងព្រៃ ។

ឆៃវ៉ាន់ៈ អត់ដឹងកន្លែងណា?

យឹមៈ អត់ដឹងកន្លែងណា...ហើយសាតណឹងក៏ដោយដែរ ។

ឆៃវ៉ាន់ៈ ដៃហ្អស់?

យឹមៈ ដៃមួយ សាតមួយ ។

ឆៃវ៉ាន់ៈ អ៊ំឃើញណឹងឃើញតាសាតឬតាដៃ?

យឹមៈ តាដៃ..តាសាតណឹងអតមានមុខមាត់ទេហៅគ្នាទៅសម្លាប់ ។

ឆៃវ៉ាន់ៈ អត់ដឹងរឿងអ៊ីហេតុអីទេ?

យឹមៈ អត់ដឹងរឿងអីហេតុអីទេ ដឹងគេគំនំគំគួនម៉េចទេពួកសហករណ៍ណឹង ។

ឆៃវ៉ាន់ៈ អ្នកដែលហៅទៅណឹងពីណាគេ?

ឃឹមៈ ឈ្មោះ ឡាប គាត់ងាប់បាត់ហើយ ។

ឆៃរ៉ាន់ៈ ឡាបណឹងអ្នកចាប់ទេ ?

ឃឹមៈ គេមានបញ្ជាអោយមកចាប់ ។

ឆៃរ៉ាន់ៈ ក្រៅពីណឹងអ៊ំមានឃើញពីណាទៀតទេ?

ឃឹមៈ អត់ទេ អ៊ំងអត់ដែលទៅណាផងអ៊ំនៅតែការដ្ឋាន ។

ឆៃរ៉ាន់ៈ ចុះអ្នកធ្វើការនៅការដ្ឋានជាមួយអ៊ំណឹងអ៊ំដែលឃើញធ្វើៗការបាត់ខ្លួនទេ?

ឃឹមៈ ទេមិនដែលឃើញបាត់ខ្លួនទេ អ្នកធ្វើនៅការដ្ឋានជាមួយខ្ញុំ ២,៣ នាក់ណឹងណា ៣ នាក់
មានយាយចាស់មួយគាត់មើលកូនឲ្យខ្ញុំកូនខ្ញុំអាទី ២ណឹង ។ កាលណឹងខ្ញុំមានកូន ១ ទៀត
ហើយ គាត់មើលកូនឲ្យខ្ញុំទៅ ខ្ញុំរុញភ្លើងបបរអីទៅចិតបន្លែចិតអីទៅ
គេមិនឲ្យធ្វើចុងភៅគ្នា ច្រើនទេខាតការងារគេណាកូន ។ គេឲ្យធ្វើតែ ២នាក់,៣
នាក់បានហើយ បបរ ២ ខ្ទះនោះ អ៊ំតែឯងដងទឹកផងខសផង ។

ឆៃរ៉ាន់ៈ ចុះអ៊ំពួកនារតីចូលមកណឹងគេមានផ្លាស់ប្តូរមេដឹងនាំក្នុងភូមិឃុំអីទេ?

ឃឹមៈ អត់..ផ្លាស់ប្តូរអត់ទាន់ផង ។

ឆៃរ៉ាន់ៈ គ្រាន់ចូលមកបានបន្តិចពួកវៀតណាមចុលមក?

ឃឹមៈ ហ្នឹងហ្អើយមិនទាន់បានជាស្អីផង វៀតណាមមក..មកបែកបាក់គ្នារត់ព្រឹបបែកគ្នារតាត់រ
តាយ បាញ់គ្នាគឹបៗ ។

ឆៃរ៉ាន់ៈ បាទ! ចុះអ៊ំរត់ទៅដល់ណាទៅ ?

ឃឹមៈ រត់ទៅដល់អីណាអីណីស្អីគេ...វៀតណាចូលមកខ្មែរក្រហមវាគៀទៅអីណោះទៀត ។

ឆៃរ៉ាន់ៈ គៀទៅដល់ណាទៅ ?

ឃឹមៈ ខ្មែរក្រហមអី នារតីគៀទៅទៀត ។

ឆៃរ៉ាន់ៈ នារតីគៀទៅ ...?

យឹមៈ នារតីយកទៅគីឡូ ៨ ដងទង់ ផ្លូវមាស អូល្ហូន ស្រែស្តៅ អីណាណោះដើតាំងយប់ទាំងថ្ងៃ ណាកូនដើរ ៣ យប់ ៣ ថៃក្តៅរងៀស ខ្លះអត់ស្បែកជើងពងជើងពងអីណា៎ វេទនាណា កូនពួកអំណា…។

នៃរ៉ាន់ៈ ហើយជម្លៀសទៅដល់ណាទៅ..?

យឹមៈ ជម្លៀសទៅដល់ណឹងទៅយួនគេទៅរំដោះមោ៉វិញ យើងទៅនៅក្នុងព្រៃទៅយួនហើយ នឹង ខ្មែរក្រហមវាបាញ់គ្នាឆាប់គរជើងគ្នា ។
មោ៉វិញពួកអំអត់មានត្រូវទេពួកអំទៅនៅមាដុប ពួកគេទៅនៅមាដុប
ហើយបាញ់អាពួកណឹងពីមាត់ស្ទឹងណឹងទៅ គេហៅកំពង់រាប១ណា ។
បាញ់កូនហ្អើយមោ៉វិញក្រឡុងខ្មោច និយាយសំពត់ខោអាវមុងភួយចាននាំងសក្បោះ សក្បាចគ្មានអ្នកណាចង់បានទេ ។

នៃរ៉ាន់ៈ ហឹអំមោ៉ដល់ផ្ទះវិញឆ្នាំណា?

យឹមៈ មោ៉ដល់ផ្ទះវិញអត់ដឹងឆ្នាំណា អត់ដឹងដែរ ។

នៃរ៉ាន់ៈ ៧៩ ហ្អែស?

យឹមៈ ….?

នៃរ៉ាន់ៈ អំគេគៀទៅយូរដែរហ្អែស៎?

យឹមៈ អត់ទេមិនយូរទេកូន ។

នៃរ៉ាន់ៈ ប្រហែលរយៈពេលប៉ុន្មាន?

យឹមៈ រយៈពេលមិនដល់ ១ ខែផង ដំបូងគេគៀទៅគេដាក់នៅទឹកសាប ដេកនៅទឹកសាប ២,៣ ,៤ យប់ទៅទៀត ទៅដល់កំពង់រាប ទៅដល់កំពង់រាបដេកបាន ៣ យប់ដឹកត្រង់សេ បាន ២,៣,៤យប់ ហកគេឲ្យទៅណោះទៀតហើយ ។ ទៅដល់ដូល្ហូន ទៅ ៣,៤ យប់គេឲ្យទៅ នៅកំពង់រាប ទៅដល់កំបង់រាបដេក ១ យប់គេឲ្យទៅទៀតហើយ ។ទៅទៀតដើរ ១យប់ ១ថ្ងៃទៀតដល់អីណាណោះ ជិតដល់សុខ សាន្ត អីចឹងក៏នៅអីណឹងទៅក៏យួនរំដោះ យួនគេទៅថាកងទ័ពវៀតណាមមោ៉ហើយ គេរំដោះយើងទៅហើយនៅទីក្រុងសម្បាយ ហើយ ។

នៃរ៉ាន់ៈ ចុះអំធ្លាប់ឆ្លងកាត់សម័យណឹងអីចឹងអំគិតថាសម័យខ្មែរក្រហមណឹងយ៉ាងម៉េចដែរ?

យឹមៈ ពិបាក ។

នែរ៉ាន់ៈ ពិបាកយ៉ាងម៉េចទៅ ?

យឹមៈ ពិបាកវាអត់ស៊ី វារត់ដើរ ចូលក្នុងព្រៃ វាបញ្ឆោឲ្យយើងស៊ី មិនថាជាស្អី មិនឲ្យស៊ីរហេតុ រហូតឲ្យស៊ីមានម៉ោងមានពេលវាពិបាកណាស់ ។

នែរ៉ាន់ៈ បាទ! ពិបាកត្រង់ណឹង?

យឹមៈ ពិបាកស៊ីពិបាកធ្វើ ។

នែរ៉ាន់ៈ ចុះអ៊ំ ដោយសារធ្លាប់ឆ្លងកាត់សម័យណឹងអីចឹងអ៊ំ ធ្លាប់និយាយរឿងណឹងឲ្យកូនចៅ អីឲ្យដឹងដែរឬក៏អត់ទេ?

យឹមៈ ដែល..កូនចៅដឹងអស់ហើយ ។

នែរ៉ាន់ៈ និយាយទៅកូនចៅ ជឿដែរអត់ទេ?

យឹមៈ និយាយទៅកូនចៅ វាថាម៉ែ ហ្អើយកុំនិយាយអីខ្ញុំមិនចង់ស្តាប់ទេអីចឹងៗ អីនោះ ។

នែរ៉ាន់ៈ ថីបានមិនចង់ស្តាប់?

យឹមៈ វាមិនចង់ស្តាប់ពូថាអត់ស៊ីរហេមរហាមនោះណាកូន...វាថាម៉ែឯងនិយាយអីទេពូតែថា ស៊ីបបរម៉ាឆ្នាំទល់ម៉ាឆ្នាំ ។

នែរ៉ាន់ៈ អាណឹងកូនអត់ជឿឬក៏ម៉េច?

យឹមៈ កូនវាជឿ តែមិនឲ្យនិយាយពូវាអាណិតម៉ែ...

នែរ៉ាន់ៈ អូ!

យឹមៈ អាណិតខ្លួនពីតូចម៉ោស៊ីតែបបរ...

នែរ៉ាន់ៈ បា!អីចឹងកូនជឿដែរហ្អែស?

យឹមៈ កូនជឿដែរ ។

នែរ៉ាន់ៈ ក្រោយម៉ោអ៊ំមានកូន ២នាក់ទៀតហ្អែ?

យឹមៈ កូន ២ នាក់ទៀត ។

នែរ៉ាន់ៈ ចុះអ៊ំមានដែលដឹងពីពត៌មានអំពីតុលាកាកាត់ទោសមេដឹកនាំខ្មែរក្រហមដែរអត់?

យឹមៈ អ៊ំអត់មានរ៉ាយូស្តាប់ផង ។

នែរ៉ាន់ៈ អត់ដែលទេ..! ចុះមានដែលពូអ្នកនៅស្រុកភូមិនេះគេនិយាយទេ?

យឹម៖ មិនដែលឮផងកូន ។

នៃរ៉ាន់៖ អត់ដែលឮគេថាមានបង្កើតតុលាការអីទេ?

យឹម៖ អត់ទេ ឮគេថានិយាយដែរតែអ៊ំមិនដែលបានដើរផ្ទះគេ ។

នៃរ៉ាន់៖ ឮគេនិយាយដែរហ្អស៎?

យឹម៖ ចា៎! ឮគេនិយាយខ្លះៗថាគេបង្កើតតុលាករវាស្រួលអីចេះណាស៎

យើងចង់ទៅ រៀនត្រង់ណា គេមិនយកលុយ..ឮគេនិយាដែរតែអ៊ំមិនបានស្តាប់គេ ។

នៃរ៉ាន់៖ ចុះអ៊ំយល់យ៉ាងម៉េចដែរចំពោះការបង្កើតសាលាក្តីកាត់ទោសមេដឹងនាំខ្មែរក្រហមណឹង?

យឹម៖ អ៊ំយល់ម៉េចទេអ៊ំអ្នកអត់អ៊ំយល់ទៅមិនរួចទេណាកូន

បើអ៊ំឈានទៅៗវាមិនរួចទេណាកូន ។

នៃរ៉ាន់៖ ចុះអ៊ំចង់ឲ្យមានការកាត់ទោសណឹងដែរឬក៏អត់ទេ?

យឹម៖ អត់ដឹង...អ៊ំអត់ដឹង ។

នៃរ៉ាន់៖ ដូចថាអ៊ំមានបាត់បង់សាច់ញាតិប៉ុន្មាននាក់ក្នុងសម័យខ្មែរក្រហម?

យឹម៖ មានដឹងបាត់បង់សាច់ញាតិប៉ុន្មាននាក់អីខ្ញុំដឹងតែបាតបង់ប្អូនខ្ញុំ ១ ណឹង ។

នៃរ៉ាន់៖ បាត់តែ ១ ណឹងទេ...?

យឹម៖ ចា៎! ដែលបាត់មិនដឹងខ្លួនថាងាប់ បើអ្នកងាប់ដឹងហើយ ។

នៃរ៉ាន់៖ ចុះអ៊ំមានបាត់ប្អូនក្នុងជំនាន់ខ្មែរក្រហមអីចឹងអ៊ំចង់ឲ្យគេរកយុត្តិធម៌ឲ្យដែរអត់ ។

យឹម៖ ចង់ឲ្យគេរកណាកូន ។

នៃរ៉ាន់៖ អីចឹងចំពោះចិត្តអ៊ំផ្ទាល់អ៊ំចង់ឲ្យមានការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមណឹងដែរ ឬក៏ម៉េច?

យឹម៖ អត់ដឹង..ដឹងតែឲ្យគេគាត់ដឹងអត់អី..

នៃរ៉ាន់៖ អ៊ំអត់យល់នែស៎?

យឹម៖ អ៊ំអត់យល់ ។

នៃរ៉ាន់៖ ក្នុងចិត្តអ៊ំៗអត់មានគិតសោះហ្អែស៎?

យឹម៖ អត់គិអីសោះ...អ៊ំអត់ចេះគិត ។

នៃរ៉ាន់៖ ចុះអ៊ំយល់ម៉េដែរចំពោះពាក្យថាយុត្តិធម៌អ៊ំ?

យឺមៈ យុត្តិធម៌យល់ដាល្អវិញ ។

ឆៃវ៉ាន់ៈ បាទខ្ញុំដូចអស់អីចង់សួរអ៊ំ ហើយអ៊ំមានអីចង់បញ្ជាក់នូវអ្វីដែលខ្ញុំអត់បានសួរអ៊ំដែរទេ?

យឺមៈ អតចង់បញ្ជាក់អីទេ អ៊ំចង់បញ្ជាក់ថាបើបានឮដំណើងប្អូនអ៊ំណើងឲ្យដំណើងម៉ោអ៊ំផង ឲ្យអ៊ំបាន ដឹងបានជ្រាប ។

ឆៃវ៉ាន់ៈ បាទ!

យឺមៈ អ៊ំចង់បញ្ជាក់តែប៉ុណ្ណើងទេកូន ។

ឆៃវ៉ាន់ៈ បាទ! ខ្ញុំជំរាបអ៊ំម្តងទៀតដូចជាពួកខ្ញុំណើងមានតែឯកសារគាត់ ដែលគេចាប់ខ្លួនគាត់កាលពី ៧៨ ណើងហ្អាស៎ ។ ដូចខ្ញុំជំរាបអ៊ំពីដើមអីចឹងថា គេបញ្ជូនទៅទួលស្លែង..ចំពោះពត៌មានអី ដែលថាគាត់នៅរស់ឬក៏ ស្លាប់អីខ្ញុំអត់ដឹងទេ តែគ្រាន់តែខ្ញុំចង់បញ្ជាក់លោកអ៊ំថាអ្នកដែល បញ្ជូនទៅទួលស្លែងភាគច្រើនកំរ៉ែរស់ណាស់.. ។ ភាគច្រើងស្លាប់ហើយ ព្រោះកន្លែងណើងជា គុកធំរបស់ខ្មែរក្រហម ។

យឺមៈ ចា៎!គុកធំរបស់ខ្មែរក្រហម ។

ឆៃវ៉ាន់ៈ អីចឹងអ៊ំមានអីឆ្ងល់ដែរអត់?

យឺមៈ អត់មានអីឆ្ងល់ទេ គ្រាថាដឹងដំណើងអីស្លាប់មែនឬក៏រស់មែនណាកូន កូនឲ្យដំណើងម៉ោអ៊ំ ព្រោះអីជីវភាពអ៊ំវាខ្សត់ខ្សោយណាស់អីចឹងអ៊ំចង់ដឹងតែប៉ុណ្ណើងឯង ។

ឆៃវ៉ាន់ៈ បាទ! បើអីចឹងអរគុណលោកអ៊ំច្រើនហើយលោកអ៊ំ ។

យឺមៈ ចា៎! អរគុណកូនហើយកូន...

ឆៃវ៉ាន់ៈ អរគុណលោកអ៊ំច្រើនដែលបាននិយាយរឿងរ៉ាវរបស់លោកអ៊ំបានដឹង ។

យឺមៈ ហើយអ៊ំចង់ឆ្ងល់ថា ដែលកូនយកពត៌មានពីអ៊ំថាតើចង់ដឹងថាយ៉ាងណាខ្លះ...

ឆៃវ៉ាន់ៈ បាទ!ពួកខ្ញុំនេះអ្នកចងក្រងប្រវត្តិសាស្ត្រក្នុងរបបខ្មែរក្រហម ហើសំរាប់ដំណើការកាត់ទោស មេដឹងនាំខ្មែរក្រហមណើង ។ បើសិនជាគេមើលឃើញឯកសារពួកខ្ញុំណើងចាំបាច់សំរាប់ជា សាក្សីអីណើងគេប្រើប្រាស់ឯកសារពួកខ្ញុំណើង ដូចខ្ញុំសម្ភាសន៍លោកអ៊ំអីចឹងណាស៎ ។

យឺមៈ ចា៎!

ឆៃវ៉ាន់ៈ ហើពួកខ្ញុំគ្រាន់តែយកពត៌មានអីចឹងទេ ហើយសរសេរជាសៀវភៅ សរសេរជាទស្សនាវដ្តី ឬក៏ចុះកាស្សែតអីចឹងណាស៎អ៊ំណា ។

ឃឹម:	ចាំ!

ឆៃវ៉ាន់:	ណឹងការងារពួកខ្ញុំតែប៉ុណ្ណឹងគឺដើម្បីជាប្រវត្តិសស្រ្តដែលទាក់ទងនឹងសម័យខ្មែរក្រហម ។

ឃឹម:	អីចឹងអ៊ំសួរកូនឯងថាកូនយកពត៌មានពីអ៊ំទៅក្រែងថាអ៊ំម៉េចៗអី...

ឆៃវ៉ាន់:	អត់ទេអ៊ំពួកខ្ញុំជាអង្គការក្រៅរដ្ឋាភិបាលប្រមូលពត៌មានណឹងមោ៉ដើម្បីសរសេរជាប្រវត្តិសាស្រ្ត ។ហើយខ្ញុំមោ៉ជួបអ៊ំណឹងមិនមែនមោ៉ជួបតែអ៊ំម្នាក់ទេ មានជួបអ្នកផ្សេងច្រើនទៀត ព្រោះខ្ញុំចុះមោ៉តាមប្រវត្តិរូបដែលមានណាអ៊ំ ។

ឃឹម:	ចាំ!

ឆៃវ៉ាន់:	ដូចនៅឃុំកំពង់គល់ណឹងខ្ញុំមាន ២ នាក់ នៅក្នុងភូមិចា ១ ទៀត ហើយខ្ញុំចុះមោ៉ណឹងដើម្បីប្រមូលសាច់រឿងទាំងអស់ណឹងយកទៅសរសេរពីតំបន់ណឹងពីភូមិឃុំណឹង ។ បើសិនជាសាច់រឿងណឹងវាគ្រប់គ្រាន់ណាស់ខ្ញុំអាចសរសេរជារឿងរ៉ាវសម័យខ្មែរក្រហមទាក់ទងទៅភូមិ ឃុំរបស់លោកអ៊ំណឹង ..។

ឃឹម:	ចាំ!

ឆៃវ៉ាន់:	ណឹងសាច់រឿងដែលពួកខ្ញុំចុះមោ៉ណឹងដេម្បីអីចឹងណាលោកអ៊ំ ។

ឃឹម:	ចាំ! អីចឹងអ៊ំសួរកូនឯងមួយទៀត...អីចឹងកូនឯងអត់ដឹងថាប្អូនអ៊ំស្លាប់ឬរស់អីចឹងកូនបានដីណឹងនេះមោ៉ពីណា?

ឆៃវ៉ាន់:	បាទប្រវត្តិរូបនេះ ប្រវត្តិរូបរបស់ប្អូនអ៊ំ ឈ្មោះ ផាន់ ហៅ អេងនេះហ្អាស់ គឺគេឲ្យធ្វើប្រវត្តិរូបពេលគេចាប់គាត់ទៅទួលស្លែងឆ្នាំ ៧៨ ។ ប្រវត្តិរូបណឹងសល់តាំងពីឆ្នាំ ៧៨ មោ៉មិនមែនពួកខ្ញុំសរសេររាល់ថ្ងៃនេះទេ

ប្រវត្តិរូបណឹងគឺនៅសេសសល់បន្ទាប់ពីខ្មែរក្រហមវាចាញ់ សង្រ្គាមណាស់អ៊ំ

ហីមួយចំនួនវាដុតចោលមួយចំនួនទៀតវាអ ត់បានដុតចោលទេ ។ អីចឹង

អ្វីដែលនៅសេសសល់ណឹងពួកខ្ញុំប្រម៉ែប្រមូ៉លជាមួយរដ្ឋាភិបាលទុកវាជាឯកសារ

ហើយពួក ខ្ញុំចុះមោ៉ស្រាវជ្រាវតាមភូមិឃុំណឹង ចង់ដឹងពីលោកអ៊ំវិញថាតើឈ្មោះ អេង

ណឹងបានត្រ ឡប់មោ៉ផ្ទះវិញដែរអត់ ។ ហើយមានពត៌មានអីខ្លះទាក់ទង

នឹងគាត់កាលសម័យខ្មែរក្រហម គាត់ធ្វើអី គាត់ការ គាត់មានកូនប៉ុន្មាននាក់អីចឹង

ដូចអ៊ំនិយាយរៀបរាប់ឲ្យខ្ញុំដឹងមុិញអីចឹង ។ តែប៉ុណ្ណឹងពួកខ្ញុំចង់បានពត៌មានអីចឹងទៅវិញ

ដើម្បីបញ្ជាក់ថាឈ្មោះណឹងដូចតាមប្រវត្តិរូប អីចឹងមែន ។ ធ្វើខាងកាំភ្លើងធំអីចឹងមែន

ហើយអ៊ំក៏ដឹងថាអីចឹងដែរ ដើម្បីបញ្ជាក់ថាអា ណឹងវាពិតហ្មាស់ ។

អ៊ំមានអីឆ្ងល់ទៀតដែរអត់?

យឹមៈ អ៊ំឆ្ងល់តែប៉ុណ្ណឹង ដែលកូនមៅសុំពត៌មានពីអ៊ំក្រែងលោវាមានរឿងរ៉ាវម៉េចអី...

នៃរ៉ាន់ៈ អត់ទេអ៊ំ ...គ្រាន់តែដើម្បីជាប្រវត្តិសាស្រ្តទេ...

យឹមៈ ខ្លាចមានខុសគ្គអីចឹងណាកូន...

នៃរ៉ាន់ៈ អត់ទេអ៊ំ គ្រាន់តែដើម្បីចង់សរសេរជាប្រវត្តិសាស្រ្តទុកឲ្យក្មេងៗក្រោយៗនេះបានរៀនបានសូត្រ អោយដឹងពីរបបណឹងឲ្យច្បាស់ ព្រោះអីក្មេងមួយចំនួននិយាយពីរបបណឹងវាអត់ជឿទេ អត់ជឿថាមានរបបខ្មែរក្រហមទេ ។ អត់ជឿថាជំនាន់ណឹងគេធ្វើការច្រើនហួបបបរអីអត់ជឿទេ ។ អីចឹងដើម្បីឲ្យវាជឿដល់តែមៅសម្ភាសន៍អ៊ំដែលឆ្លងកាត់សម័យណឹងហើយសរសេរជាសៀវភៅឲ្យវារៀនឲ្យវាយល់ទៅថ្ងៃក្រោយទៅវាជឿណាអ៊ំ ។ ហើយក្មេងៗជឿថាមានរបបណឹងអីចឹងវាជួយការពារកុំឲ្យមានរបបណឹងម្តងទៀតដូចថាបើវាយល់ច្បាស់ទៅ វាមិនអាចមានរបបអីចឹងកើឡើងទៀតទេ បើសិនជាវាយល់ច្បាស់ ។ អីចឹងពត៌មានដែលពួកខ្ញុំចុះមៅណឹងគឺអីចឹងឯង ។ ដើម្បីសរសេរជាប្រវត្តិសាស្រ្តណាអ៊ំក៏ដូចប្រវត្តិសាស្រ្តសម័យអង្គរ ប្រវត្តិសាស្រ្តពីអីណឹងគេធ្វើអីចឹង ។ ហីអ៊ំមានឆ្ងល់អីទៀតដែរ?

យឹមៈ អ៊ំឆ្ងល់តែប៉ុណ្ណឹងឯងបានអ៊ំសួរកូនឯងណឹង
ហីកូនឯងសូមស្រាវជ្រាវក្រែងលោទៅក្រៅទៅ
អីនៅអីណាអូនឯងជួយស្រាវជ្រាវផង ។

នៃរ៉ាន់ៈ បាទ!

យឹមៈ ព្រោះអីអ៊ំអត់ដឹងដិណឹង នឹងឃើញថាបើទឹងដោះម្តាយថ្ងៃវាមិនស្លាប់ អីចឹងណាកូន ។

នៃរ៉ាន់ៈ អីចឹងអរគុណលោកអ៊ំច្រើនអ៊ំណា៎ ។

-ចប់-